# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបនីតិវិធីចុះបញ្ជីប្រកាសនីយបត្រ តក្កកម្មនៅកម្ពុជា និង តាមសន្ធិសញ្ញា សហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **នួន កន្និកា**

សាស្ត្រាចារ្យណែនាំ
លោក **ឃឹម គីរី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **នួន ភន្និភា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ជំនាន់ទី២៤ ឆ្នាំសិក្សា២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ជាបឋម នាងខ្ញុំសូមលំឱនកាយនូវកតញ្ញូតាធមយ៉ាងជ្រាលជ្រៅ និង ខ្ពង់ខ្ពស់ជាទីបំផុត ចំពោះលោកឪពុកអ្នកម្តាយ ដែលលោកបានបង្កើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំណែនាំ ប្រៀបប្រដៅ លះបង់គ្រប់យ៉ាង ដើម្បីឲ្យនាងខ្ញុំមានឱកាសបានសិក្សារៀនសូត្ររហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្រ្តចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាខិតខិបង្ហាត់បង្រៀន និងចែករំលែកនូវចំណេះដឹងព្រមទាំងបទពិសោយធន៍ល្អៗដល់នាងខ្ញុំតាំងពីដើមរហូតមកដល់ពេលនេះ។

ជាពិសេសនាងខ្ញុំសូមគោរព និងថ្លែងអំណរគុណ ចំពោះ លោកសាស្រ្តចារ្យ **ឃឹម គីរី** ជាសាស្រ្តាចារ្យដឹកនាំក្នុងការសរសេរសារណានេះឡើង ដោយលោកបានខិតខំចំណាយពេលវេលា ដ៏មានតម្លៃ ធ្វើការណែនាំពន្យល់អំពីចំណុចសំខាន់ៗ បង្ហាញពីរបៀបសរសេរ ផ្តល់ជាមតិយោបល់ល្អៗ ឯកសារដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ ព្រមទាំងជួយពិនិត្យ និងកែតម្រូវលើចំណុចខ្វះខាតទាំងឡាយ ដើម្បីជម្រុញឲ្យសារណារបស់នាងខ្ញុំទទួលបាននូវលទ្ធផលល្អប្រសើរ។

ជាទីបញ្ចប់ នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិ សូមប្រសិទ្ធិពរជ័យដល់ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី និងលោកសាស្រ្តចារ្យ **ឃឹម គីរី** ទទួលបាននូវសុខភាពល្អ និងទទួលបាននូវជោគជ័យគ្រប់ភារៈកិច្ចទាំងអស់។

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាមានច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលបានប្រកាសឲ្យប្រើប្រាស់ជាស្ថាពរនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលរៀបរាប់អំពីការការពារ និង ការទទួលបានសិទ្ធិបន្ទាប់ពីបានចុះបញ្ជី។ យ៉ាងណាមិញ ចំពោះនីតិវិធីដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្មត្រូវបានចែងក្នុងប្រកាសលេខ ៧០៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មកស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ ។

លើសពីនេះទៅទៀត ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតកក្កកម្មនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ ដែលត្រូវបានបង្កើតឡើងនៅរដ្ឋធានីវ៉ាស៊ីនតោននាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ និងត្រូវបានធ្វើវិសោធនកម្ម នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩ ព្រមទាំងធ្វើការកែសម្រួលឡើងវិញ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៨៤ និងនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០១។ សន្ធិសញ្ញានេះក៏មានចែងអំពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្មជាលក្ខណៈអន្តរជាតិជាមួយនឹងប្រទេសជាសមាជិកនៃសន្ធិសញ្ញា ដែលប្រទេសជាសមាជិកគ្រាន់ដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មអន្តរជាតិតែមួយប៉ុណ្ណោះ ដោយពុំចាំបាច់ដាក់ពាក្យសុំច្រើនដងនៅតាមប្រទេស ឬតំបន់ផ្សេងៗគ្នាឡើយ។

ដោយមើលឃើញពីលក្ខណៈពិសេស និង ភាពខុសគ្នារវាងនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និង ការចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតកក្កកម្ម និងបន្ទាប់ពីពិភាក្សាជាមួយនឹងលោកសាស្ត្រាចារ្យព្រម ទាំងទទួលបានការលើកទឹកចិត្តពីសាស្ត្រាចារ្យណែនាំផងនោះ ទើបនាងខ្ញុំសម្រេចចិត្តសរសេរសារណា ទាក់ទងនឹងប្រធានបទ "**ការប្រៀបធៀបនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និង តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**"។ ក្នុងនោះ ផងដែរ នាងខ្ញុំសង្ឃឹមថា សារណានេះនឹងក្លាយជាឯកសារដែលអាចផ្តល់នូវចំណេះដឹងដ៏មានតម្លៃពាក់ព័ន្ធនឹង នីតិវិធីក្នុងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មសម្រាប់និស្សិត និងអ្នកស្រាវជ្រាវដទៃទៀត។ យ៉ាងណាមិញ ចំពោះសារណាមួយនេះ នាងខ្ញុំជឿជាក់ថា ពិតជាមាននូវកំហុសឆ្គង និងកង្វះខាតមួយចំនួនដោយជៀសមិនផុតឡើយ ទាំងលើខ្លឹមសារ និងអក្ខរាវិរុទ្ធ។ ហេតុនេះនាងខ្ញុំសូមអភ័យទោសនូវរាល់កំហុសដែលខ្វះខាត និងរង់ចាំទទួលយកនូវការរិះគន់ និង ការណែនាំបន្ថែមទៀតពីសំណាក់លោកសាស្ត្រាចារ្យ សិស្សនិស្សិត និងអ្នកសិក្សាទាំងអស់ដើម្បីស្ថាបនាស្នាដៃនេះឲ្យកាន់តែល្អប្រសើរឡើង។

# **អំណះអំណាង**

នាងខ្ញុំឈ្មោះ **នួន កន្និកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា២០១៥ ដល់ឆ្នាំ២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការអះអាងចំពោះខ្លឹមសារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ នេះពិតជាកើត ចេញពីគំនិតផ្ទាល់ខ្លួនរបស់នាងខ្ញុំ និងដោយបានការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ **ឃឹម គិរី** ទាំងឯកសារស្មារតី និង ការពន្យល់បង្ហាត់បង្ហាញ ដែលធ្វើឱ្យនាងខ្ញុំមាន ទុននៅក្នុងការសរសេរសារណានេះឡើង ដោយមិនមានការថតចម្លងសារណា ឬ របាយការណ៍ ឬ និក្ខេបបទ របស់អ្នកផ្សេងឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៩

**ហត្ថលេខា**

**នួន កន្និកា**

# មូលវិចារណ៍

ខ្ញុំសូមកោតសរសើរចំពោះនិស្សិត **នួន កន្និកា** សិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី២៤ ដែលកំពុងសិក្សានៅសាកវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំព្យាយាមយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ការរៀបចំរៀបនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និង តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**" ។

មតិវិភាគទាំងឡាយក្នុងឯកសារ គឺជាស្នាដៃ និង ជាគំនិតផ្ទាល់ខ្លួនរបស់និស្សិត ដែលបានមកពីការសិក្សាស្រាវជ្រាវកន្លងមក ក្នុងស្មារតីស្វែងយល់ពីទ្រឹស្តី យន្តការ និងដំណើរការនៃនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និង តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលវាមានលក្ខណៈពិសេសរៀងៗខ្លួនសម្រាប់អនុវត្តន៍ជាក់ស្តែងក្នុងវិស័យកម្មសិទ្ធិបញ្ញា នា ពេលបច្ចុប្បន្ននេះ។

ជាចុងបញ្ចប់ក្នុងនាមជាសាស្រ្តាចារ្យណែនាំក្នុងការសរសេរសារណានេះ យល់ឃើញថា សារណានេះនឹងក្លាយជាឯកសារជំនួយស្មារតីដ៏មានតម្លៃ និង មានសារៈប្រយោជន៍ដល់និស្សិត និងអ្នកស្រាវជ្រាវដទៃទៀតដើម្បីធ្វើជាទុនក្នុងការស្រាវជ្រាវ បន្ថែមទៀតបាននាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៩

**ហត្ថលេខា**

**សាស្រ្តាចារ្យ ឃឹម គិរី**

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**.......................................................................................១

**ជំពូកទី១. សញ្ញាណទូទៅនិង សមត្ថកិច្ចទទួលបន្ទុក**.................................................៣

១.១. សញ្ញាណទូទៅប្រកាសនីយបត្រតក្កកម្មកម្ពុជា ........................................................ ៣

១.២. សញ្ញាណទូទៅសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ...........................៣

១.៤. សមត្ថកិច្ចទទួលបន្ទុកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម................៤

១.៤.១សន្និបាត .............................................................................................៥

១.៤.២ គណៈកម្មការប្រតិបត្តិ .............................................................................៥

១.៤.៣ ការិយាល័យអន្តរជាតិ .............................................................................៥

១.៤.៤-គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស .......................................................៦

**ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីនៅកម្ពុជា**........................................................៧

២.១. សំណុំឯកសារចាំបាច់សម្រាប់ដាក់ពាក្យសុំ ......................................................... ៧

២.១.១ ពាក្យសុំ...............................................................................................៨

២.១.២ សេចក្តីអត្ថាធិប្បាយ .................................................................................៨

២.១.៣ សេចក្តីអះអាង .......................................................................................៨

២.១.៤ ខ្លឹមសារសង្ខេបនៃតក្កកម្ម .........................................................................៩

២.២. ការត្រួតពិនិត្យលិខិតស្នើសុំចុះបញ្ជី.....................................................................៩

២.២.១ ការពិនិត្យលិខិតលើពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម.......................................៩

២.២.២ ការត្រួតពិនិត្យលំអិត..............................................................................១០

២.៣. ការសម្រេចលើប្រកាសនីយបត្រតក្កកម្ម..............................................................១០

២.៣.១ ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម.........................................១១

២.៣.២ ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម ........................................................១១

**ជំពូកទី៣ នីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម**..........................................................................................១៣

៣.១. ការដាក់ពាក្យស្នើសុំអន្តរជាតិ ........................................................................ ១៣

៣.១.១. ពាក្យស្នើសុំអន្តរជាតិ ............................................................................ ១៣

៣.១.២. ការដាក់ពាក្យស្នើសុំអន្តរជាតិ ....................................................................១៥

៣.២. ការស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ........................................ ១៨
៣.២.១ ស្រាវជ្រាវអន្តរជាតិ ........................................ ១៩
៣.២.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិ ........................................ ២១
៣.២.៣ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ........................................ ២១
៣.៣.ការចុះផ្សាយអន្តរជាតិ ........................................ ២៣
៣.៣.១ អានុភាពនៃការចុះផ្សាយអន្តរជាតិ ........................................ ២៣
៣.៣.២ ភាសានៃការចុះផ្សាយអន្តរជាតិ ........................................ ២៤
៣.៤. នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម និង របាយការណ៍ស្រាវជ្រាវអន្តរជាតិ បន្ថែម .... ២៤
៣.៤.១ នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម ........................................ ២៤
៣.៤.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម ........................................ ២៥
៣.៥. ការពិនិត្យជំហានដំបូងអន្តរជាតិនិងរបាយការណ៍ពិនិត្យ ជំហានដំបូងអន្តរជាតិ ........... ២៦
៣.៥.១ ការពិនិត្យជំហានដំបូងអន្តរជាតិ ........................................ ២៦
៣.៥.២ របាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ ........................................ ២៨
៣.៦. ការពិនិត្យថ្នាក់ជាតិ ........................................ ២៩
៣.៦.១ សំណុំឯកសារចាំបាច់ ........................................ ៣០
៣.៦.២ ការត្រួតពិនិត្យ ........................................ ៣០
៣.៦.៣ ការកែសម្រួលនៅដំណាក់កាលនីតិវិធីកម្រិតជាតិ ........................................ ៣០

**ជំពូកទី៤. លក្ខណៈពិសេសមួយចំនួននៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម**..៣២
៤.១.ការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ........................................ ៣២
៤.១.១សមត្ថកិច្ចទទួលបន្ទុក ........................................ ៣២
៤.១.២ ការដាក់ពាក្យស្នើសុំ ........................................ ៣៣
៤.២. ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ........................................ ៣៥
៤.២.១ សមត្ថកិច្ចចុះបញ្ជី ........................................ ៣៥
៤.២.២ ការដាក់ពាក្យស្នើសុំចុះបញ្ជី ........................................ ៣៥
៤.៣.ការកំណត់គោលការណ៍និងនិតីវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ........................................ ៣៨
៤.៣.១ សមត្ថកិច្ចទទួលបន្ទុក ........................................ ៣៩
៤.៣.២ ការស្នើសុំទទួលស្គាល់សុពលភាព ........................................ ៣៩
៤.៤.ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ........................................ ៤៤

៤.៤.១ សមត្ថកិច្ចទទួលពាក្យស្នើសុំនិងចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិន..........៤៥
៤.៤.២ ការដាក់ស្នើសុំ និងចុះបញ្ជី....................................................................................៤៥
**សេចក្តីសន្និដ្ឋាន**.................................................................................................................៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

តក្កកម្ម គឺជាការរកឃើញអ្វីថ្មីរបស់តក្កករ ដែលអាចយកទៅប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា។ វាអាចជាការរកឃើញផលិតផល ឬ ដំណើរការ ផលិកម្ម ឬអាចជាការរកឃើញអ្វីមួយ ដែលទាក់ទងនឹងផលិតផល ឬ ដំណើរការផលិតផល។ តក្កកម្មនឹងត្រូវទទួលបានការការពារ លុះត្រាតែតក្កកម្មនោះបានធ្វើការចុះបញ្ជី ដោយច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនៅតាមប្រទេស ដែលតក្កករចង់ទទួលបានការការពារ។ យ៉ាងណាមិញ តក្កកម្ម ដែលអាចស្នើសុំចុះបញ្ជីបានលុះត្រាតតែតក្កកម្មនោះជាតក្កកម្មថ្មីដែលជាលក្ខណៈសម្បត្តិចម្បងដំបូងបំផុត ហើយមានជំហាននៃការច្នៃប្រឌិតថ្មី (ជំហាននៃការរកឃើញថ្មី) ដែលបុគ្គលសាមញ្ញមិនអាចយល់ដឹងបាន ហើយតក្កកម្មនោះត្រូវតែអាចយកទៅអនុវត្តន៍បាននៅក្នុងឧស្សាហកម្ម។

តក្កកម្មដែលទទួលបាននូវការពារ អាចទទួលបានផលប្រយោជន៍ជាច្រើនដូចជា តក្កករទទួលបានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងពេញលេញលើតក្កកម្មរបស់ខ្លួន ព្រមទាំងការប្រើប្រាស់ និង រកប្រាក់ចំណូលបានពីការធ្វើអាជីវកម្មលើតក្កកម្មនោះ។ តាមរយៈការការពារនេះ តក្កករនឹងទទួលបានការឈរជើងដ៏រឹងមាំក្នុងទីផ្សារ ដើម្បីទទួលបានប្រាក់ចំណូល និងផលប្រយោជន៍ច្រើនដោយសារតែវាជួយកាត់បន្ថយបាននូវការប្រកួតប្រជែងមិនស្មោះត្រង់ហើយថែមទាំងជួយឲ្យតក្កករទទួលបានប្រាក់ចំណូលខ្ពស់ពីការដាក់ទុនវិនិយោគលើគំនិតច្នៃប្រឌិតដែលជាតក្កកម្មរបស់ខ្លួននោះ។

តក្កករអាចទទួលបានការការពារតក្កកម្មរបស់ខ្លួនបាន ដោយតម្រូវឲ្យធ្វើការដាក់ពាក្យសុំនៅតាមការិយាល័យចុះបញ្ជីនៅតាមប្រទេសនីមួយៗ។ ប្រសិនបើតក្កករមានបំណងចង់ទទួលបានការការពារនៅច្រើនប្រទេស ពួកគេត្រូវធ្វើដាក់ពាក្យសុំទៅតាមនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីតាមប្រទេសនីមួយៗនោះដោយការដាក់ពាក្យសុំនេះអាចមានដំណើរការនៃនីតិវិធី និង លក្ខខណ្ឌខុសៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ ហើយត្រូវចំណាយពេលវេលា និងថវិការច្រើន ផងដែរ។ មិនតែប៉ុណ្ណោះ តក្កករទាំងឡាយអាចដាក់ពាក្យសុំចុះបញ្ជីការពារតក្កកម្មនៅក្នុងប្រទេសកម្ពុជាបានផងដែរ ដោយពួកគេត្រូវគោរពតាមច្បាប់ និងនីតិវិធីរបស់ព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកតក្កករក៏អាចទទួលបានការការពារពីបណ្តាប្រទេសជាច្រើនទៀត ប្រសិនបើពួកគេធ្វើការដាក់ពាក្យសុំតាមរយៈសន្ធិសញ្ញាអន្តរជាតិដែលមានឈ្មោះថា "សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម" ដែលសន្ធិសញ្ញានេះមានគោលបំណងជួយសម្រួលដល់តក្កករ ឬ អ្នកដាក់ពាក្យសុំដើម្បីទទួលបានការការពារលើតក្កកកម្មរបស់ខ្លួនពីបណ្តាប្រទេសជាច្រើន ជាពិសេសប្រទេសជាសមាជិកនៃសន្ធិសញ្ញានេះ។

សារណានេះ នាងខ្ញុំនឹងធ្វើការបកស្រាយអំពីនីតិវិធីចុះប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។ សារណាត្រូវបានបែងចែក ឡើងជា៤ជំពូក ដោយ ជំពូកទី១ និយាយអំពីសញ្ញាណទូទៅ និងសមត្ថកិច្ចទទួលបន្ទុក ក្នុងការចុះបញ្ជីនៃប្រទេសកម្ពុជា និងតាមសន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្ម។ ចំណែកឯជំពូកទី២ និយាយអំពីនីតិវិធីនៃការចុះបញ្ជីនៅកម្ពុជា ជំពូកទី៣ និយាយនីតិវិធី នៃការចុះបញ្ជីតាមសន្ធិសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ជំពូកទី៤ និយាយអំពី លក្ខណៈពិសេសនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មរបស់ប្រទេសមួយចំនួនជាមួយនឹងកម្ពុជា។

# ជំពូកទី១. សញ្ញាណទូទៅ និង សមត្ថកិច្ចទទួលបន្ទុក

## ១.១. សញ្ញាណទូទៅប្រកាសនីយបត្រតក្កកម្មកម្ពុជា

ប្រកាសនីយបត្រតក្កកម្មគឺ ជាវិញ្ញាបនបត្រដែលបានផ្តល់ការការពារតក្កកម្មដែលចេញដោយរដ្ឋាភិបាលនៃប្រជាជាតិមួយទៅឲ្យតក្កករ។ តក្កកម្មជាគំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា។ តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬ អាចជាការរកឃើញអ្វីមួយដែលទាក់ទងនឹងផលិតផល ឬ ដំណើរការផលិតកម្ម។[1]

គោលបំណងនៃច្បាប់ប្រកាសនីយបត្រតក្កកម្មមានដូចតទៅៈ

- លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា
- ជំរុញនិងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស និងការវិនិយោគ
- លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងប្រទេសកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្មនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច
- ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់។[2]

## ១.២. សញ្ញាណទូទៅសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (តទៅហៅកាត់ថា "សន្ធិសញ្ញា PCT") គឺជាលិខិតូបករណ៍អន្តរជាតិមួយដែលបានចុះហត្ថលេខានៅឆ្នាំ ១៩៧០ នៅរដ្ឋធានីវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ហើយមានសុពលភាព នៅឆ្នាំ១៩៧៨ នៅពេលមានប្រទេសហត្ថលេខីចំនួន ១៨ ប្រទេស។ បច្ចុប្បន្ននេះ សន្ធិសញ្ញា PCT មានប្រទេសសមាជិកចំនួន ១៥២ ប្រទេស ដែលកំពុងផ្តល់ការចុះបញ្ជីលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាលក្ខណៈអន្តរជាតិនេះ។

សន្ធិសញ្ញា PCT នេះ មានគោលបំណងចូលរួមចំណែកធ្វើឱ្យរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈៈ

- កែលម្អ និង សម្រួលនីតិវិធីដើម្បីទទួលការការពារតក្កកម្មតាមផ្លូវច្បាប់ធ្វើឱ្យមានភាពងាយស្រួល និង ធ្វើឱ្យសន្សំសំចៃចំពោះការទទួលបាននូវការការពារនូវតក្កកម្មក្នុងបណ្តាប្រទេសជាច្រើន

[1] មាត្រា ៣ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

[2] មាត្រា ២ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

- ជួយសម្រួលនិង ពន្លឿនដំណើរការនៃអាជ្ញាធរសាធារណៈចំពោះឯកសារសេចក្តីអធិប្បាយបច្ចេកទេសនៃតក្កកម្ម ជំរុញ និង ពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍតាមរយៈការអនុម័តនូវវិធាន ដែលចងក្រងឡើងដើម្បីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់សម្រាប់ផ្តល់ភាពងាយស្រួល និង រកដំណោះស្រាយបច្ចេកទេសពាក់ព័ន្ធតក្កកម្មនៅក្នុងភាពជឿនលឿននៃ បច្ចេកវិទ្យាសម័យទំនើបជាជាងយន្តការថ្នាក់ជាតិ ឬ តំបន់។ ផ្អែកលើគោលបំណងនេះ សន្ធិសញ្ញា PCT មានកម្មវត្ថុចម្បងបង្កើតឱ្យមានវិធាននៃប្រព័ន្ធចុះបញ្ជីលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មតែម្តងនៅការិយាល័យជាតិ ដើម្បីទទួលបានការការពារតក្កកម្មនៅបណ្តាប្រទេសជាច្រើន។ វិធានទាំងនោះតម្រូវឱ្យរដ្ឋហត្ថលេខី រួមគ្នាជាសហភាពភាពមួយដើម្បីធ្វើសហប្រតិបត្តិការក្នុងការដាក់សំណុំលិខិតស្នើសុំការស្រាវជ្រាវសំណុំលិខិតស្នើសុំ និងពិនិត្យសំណុំលិខិតស្នើសុំសម្រាប់ការការពាតក្កកម្ម និងសម្រាប់ផ្តល់សេវាកម្មបច្ចេកទេសពិសេស។

## ១.៣. សមត្ថកិច្ចទទួលបន្ទុកការផ្តល់ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា

ពាក្យស្នើសុំចុះបញ្ជីនេះ ត្រូវដាក់ជូនទៅនាយកដ្ឋាន កម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ នាយកដ្ឋាននេះដឹកនាំ ដោយប្រធាននាយកដ្ឋានមួយរូបដែលមានតួនាទីតាមច្បាប់នេះគឺជា មន្ត្រីកាន់កាប់បញ្ជីសម្រាប់រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងអស់។[3] ការស្នើសុំអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម (តក្ករ) ត្រូវដាក់ឈ្មោះរបស់ខ្លួនគាត់ផ្ទាល់ លើកលែងតែមានការប្រកាសជាលាយលក្ខណ៍អក្សរពិសេសណាមួយហើយផ្ញើទៅមន្ត្រីកាន់កាប់បញ្ជី ដោយបញ្ជាក់ថា គាត់ពុំមានបំណងនឹងបញ្ចេញឈ្មោះទេ។

ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មត្រូវបង់កម្រៃជាមុន ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវការត្រួតពិនិត្យជាចាំបាច់។

## ១.៤. សមត្ថកិច្ចទទួលបន្ទុកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

សន្ធិសញ្ញា PCT ស្ថិតក្រោមការគ្រប់គ្រងរបស់សន្និបាត (១.៤.១) ដែលរចនាសម្ព័ន្ធកំពូលរបស់សន្ធិសញ្ញា។ រាល់កិច្ចការធំៗពាក់ព័ន្ធនឹងសន្ធិសញ្ញាត្រូវសម្រេចដោយសន្និបាត។ បន្ទាប់ពីសន្និបាតគឺ គណៈកម្មការប្រតិបត្តិ (១.៤.២) ដែលជាជាអង្គភាពប្រតិបត្តិការងារ ជំនួសសន្និបាតនៅចន្លោះសម័យប្រជុំ ការិយាល័យអន្តរជាតិ (១.៤.៣) គឺជាអង្គភាពរដ្ឋបាល ដែលចាត់ចែងនិងដឹកនាំការងារប្រចាំថ្ងៃ និងដឹកនាំដោយអគ្គនាយកមួយរូប ចុងក្រោយ គឺគណៈកម្មការសហ

[3] ប្រការ ២ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ប្រតិបត្តិការបច្ចេកទេស (១.៤.៤) ដែលត្រូវចាត់ទុកជា អង្គភាពប្រឹក្សាយោបល់ផ្នែកបច្ចេកទេស។[4]

**១.៤.១ សន្និបាត**

រដ្ឋាភិបាលនៃរដ្ឋហត្ថលេខីនីមួយៗ ត្រូវតំណាងដោយប្រតិភូម្នាក់ និង ត្រូវមានជំនួយការអមដោយប្រតិភូស្ដីទី ទីប្រឹក្សា និងអ្នកជំនាញការមួយចំនួន។ សន្និបាតត្រូវជួបប្រជុំជាវៀងរាល់ពីរឆ្នាំម្តងនៃឆ្នាំប្រក្រតិទិន ដែលជាសម័យប្រជុំពេញអង្គតាមការកោះអញ្ជើញរបស់អគ្គនាយក។

សន្និបាតត្រូវៈ

- ចាត់ចែងគ្រប់គ្រងសកម្មភាពពាក់ព័ន្ធទៅនឹងការរក្សា និង ការអភិវឌ្ឍរបស់ និង ការអនុវត្តរបស់សន្ធិសញ្ញានេះ
- ផ្តល់បទបញ្ជាចំពោះការិយាល័យអន្តរជាតិពាក់ព័ន្ធទៅ នឹងការរៀបចំសន្និសិទដើម្បីពិនិត្យការងារឡើងវិញ
- ពិនិត្យសារឡើងវិញ និង ផ្តល់ការយល់ព្រមលើរបាយការណ៍ និង សកម្មភាពរបស់គណៈកម្មការប្រតិបត្តិ
- កំណត់កម្មវិធី និង អនុម័តថវិកាបីឆ្នាំរបស់សហភាព និងផ្តល់ការយល់ព្រមលើបញ្ជីគណនីចុងក្រោយរបស់គេ
- អនុម័តបទបញ្ញាហរិញ្ញវត្ថុរបស់
- បង្កើតគណៈកម្មការ និង ក្រុមការងារតាមដែលសន្និបាតគិតថាជាការសមស្របដើម្បីកម្មវត្ថុរបស់សម្រេចបានជោគជ័យ។[5]

**១.៤.២ គណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិត្រូវបានបង្កើតឡើង ដោយជ្រើសតាំងដោយសន្និបាតពីចំណោមរដ្ឋសមាជិក។ រដ្ឋសមាជិកនីមួយៗនៃគណៈកម្មការប្រតិបត្តិត្រូវតែតំណាងដោយប្រតិភូម្នាក់ និង ជំនួយការអមទីប្រឹក្សា និង អ្នកជំនាញការមួយចំនួន។ ចំនួនរដ្ឋដែល សមាជិកនៃគណៈកម្មការ ត្រូវមានចំនួន ១/៤ នៃចំនួនរដ្ឋដែលជាសមាជិកសន្និបាត និង ត្រូវគិតគូរទៅដល់ការបែងចែកសមធម៌តាមលក្ខណៈភូមិ សាស្ត្រ។

គណៈកម្មការប្រតិបត្តិត្រូវៈ

- រៀបចំសេចក្តីព្រាងរបៀបវារៈរបស់សន្និបាត
- ដាក់សំណើជូនសន្និបាតដែលពាក់ព័ន្ធទៅនឹងសេចក្តីព្រាងកម្មវិធី និងថវិកាប្រចាំបីឆ្នាំរបស់

[4] មាត្រា ១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ
[5] មាត្រា ៥៣ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ដែលរៀបចំដោយអគ្គនាយក

- ដាក់ជូនសន្និបាតនូវរបាយការណ៍ជាដំណាក់ៗរបស់អគ្គនាយក និង របាយការណ៍សវនកម្មប្រចាំឆ្នាំអំពីបញ្ជីគណនេយ្យជាមួយសេចក្តីសង្កេតសមស្រប
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាការប្រតិបត្តិកម្មវិធីរបស់ដោយអគ្គនាយក ដោយយោងតាមសេចក្តីសម្រេចរបស់សន្និបាត ហើយគិតទៅដល់កាលៈទេសៈដែលកើតឡើងរវាងសម័យប្រជុំពេញអង្គទាំងពីររបស់សន្និបាត
- អនុវត្តការងារផ្សេងៗទៀតដូចត្រូវបានគ្រោងទុកសម្រាប់ខ្លួននៅក្នុងក្រោមសន្ធិសញ្ញានេះ

គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំម្តងនៅក្នុងសម័យប្រជុំពេញអង្គ តាមការកោះអញ្ជើញរបស់អគ្គនាយក និង ត្រូវប្រជុំវិសាមញ្ញម្តង តាមការកោះអញ្ជើញរបស់អគ្គនាយក ឬ តាមសំណើរបស់ប្រធានគណៈកម្មការប្រតិបត្តិ ឬ សមាជិកចំនួន ១/៤ នៃចំនួនសមាជិករបស់ខ្លួន។[6]

### ១.៤.៣ ការិយាល័យអន្តរជាតិ

ការិយាល័យអន្តរជាតិ គឺអនុវត្តកិច្ចរដ្ឋបាល ដែលដឹកនាំដោយអគ្គនាយក។ អគ្គនាយក និង សមាជិកដែលបុគ្គលណាម្នាក់ដែលចាត់តាំងដោយអគ្គនាយកត្រូវចូលរួមគ្រប់ ការជួបប្រជុំទាំងអស់របស់សន្និបាតគណៈកម្មការប្រតិបត្តិនិង គណៈកម្មការផ្សេងទៀត ឬ ក្រុមការងារដែលបង្កើតសន្ធិសញ្ញានេះ។[7]

### ១.៤.៤ គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស

គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស ត្រូវបង្កើតឡើងដោយសន្និបាត។ គោលបំណងនៃការបង្កើតគណៈកម្មការនេះ ចូលរួមផ្តល់យោបល់ និង ការណែនាំ សំដៅធ្វើប្រសើឡើងជាប្រចាំនៃសេវាកម្មនានា ធានាមានសង្គតភាពក្នុងផ្តល់ឯកសារ និង វិធីសាស្ត្រ ការងារដើម្បីគុណភាពនៃរបាយការណ៍របស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ និង អាជ្ញាធរពិនិត្យ ជំហានដំបូងអន្តរជាតិ ព្រមទាំងរកដំណោះស្រាយបញ្ហាបច្ចេកទេសនានា។[8]

[6] មាត្រា ៥៤ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[7] មាត្រា ៥៥ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[8] មាត្រា ៥៦ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

## ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីនៅកម្ពុជា

តក្កកម្ម ត្រូវតែចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និង សិប្បកម្ម ដើម្បីទទួលបាននូវកិច្ចការពារស្របច្បាប់ និង ទទួលបានសិទ្ធិផ្ដាច់មុខលើតក្កកម្មនោះ។

ការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើឡើងដោយម្ចាស់តក្កកម្ម ឬ អ្នក តំណាង ស្របច្បាប់របស់ ម្ចាស់តក្កកម្ម ដោយបំពេញតាមទម្រង់ដែលកំណត់ដោយច្បាប់ និងបទ ប្បញ្ញត្តិពាក់ព័ន្ធក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

អាទិភាពនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនេះត្រូវបានផ្ដល់ឲ្យអ្នក ដែលបាន ចុះបញ្ជីជាផ្លូវការមុនគេ ឬអ្នកដែលបានអះអាងថាមានអាទិភាពនោះ។

### ២.១. សំណុំឯកសារចាំបាច់សម្រាប់ដាក់ពាក្យសុំ

សំណុំលិខិតដែលចាំបាច់បំផុតដែលតម្រូវសម្រាប់ការស្នើសុំប្រកាសនីយបត្រតក្កកម្ម មួយ រួមមាន [9] ៖ ពាក្យសុំសេចក្ដីអធិប្បាយអំពីតក្កកម្ម សេចក្ដីអះអាង គំនូសបង្ហាញ និង ខ្លឹមសារ សង្ខេបនៃតក្កកម្មនោះជាដើម។ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម គឺជា ការដាក់សំណុំ បែបបទដែលត្រូវបង់កម្រៃជាមុន ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រ តក្កកម្មត្រូវការត្រួតពិនិត្យជាចាំបាច់ចំពោះទម្រង់ និង ខ្លឹមសារសង្ខេបពីតក្កកម្មនោះ។ ក្រោយពី ការដាក់សំណុំលិខិតស្នើសុំជាលើកដំបូងមានពេលវេលារហូត១២ខែ ដើម្បីសម្រេចជ្រើសរើសយក ប្រទេសណាមួយដែលគាត់ចង់បានទទួលការការពារក្នុង ប្រទេសទាំងនោះ។

លើសពីនេះទៀត រាល់ការដាក់ពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្ម ត្រូវតែគោរពឲ្យបាន នូវវិធានឯកភាពនៃតក្កកម្ម។ វិធានឯកភាពនៃតក្កកម្មសំដៅដល់ការហាមឃាត់ចំពោះលទ្ធភាពផ្ដល់ ដល់តក្កកម្ម ច្រើននូវប្រកាសនីយបត្រតែមួយ។[10]

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិមានន័យថា តក្កកម្មទាំងឡាយណាដែល បានរកឃើញនៅក្នុងប្រទេសស្នើសុំប្រកាសនីយបត្រតក្កកម្ម។ ការស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាតិដែលបែបបទក្នុងការស្នើសុំចុះបញ្ជីត្រូវអនុលោមតាមច្បាប់ជាតិកំណត់។ ជាធម្មតានៅពេលដែល រកឃើញតក្កកម្មមួយចាំបាច់ត្រូវស្នើសុំការការពារដោយបែបបទនៃការស្នើសុំនេះមានដូចតទៅ៖

#### ២.១.១ ពាក្យសុំ

អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់ក្នុងពាក្យសុំឲ្យបានច្បាស់លាស់ពីអ្វី ដែលអាចឈានទៅដល់

[9] ប្រការ ១៦ នៃប្រកាសលេខ ៧០៦ ស្ដីពីនីតិវិធីផ្ដល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[10] មាត្រា ២៣ នៃច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

ការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មបានរួមទាំងទិន្នន័យដែលពាក់ព័ន្ធទៅនិងតក្កករ និងភ្ជាប់មកជាមួយនូវចំណងជើងរបស់តក្កកម្ម។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនមែនតក្កករ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់មកជាមមួយនូវឯកសារបញ្ជាក់ពីការផ្ទេរសិទ្ធិភ្ជាប់មកជាមួយផង។

ពាក្យសុំត្រូវបង្ហាញនូវព័ត៌មានដែលទាក់ទងទៅនឹងឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋានរបស់អ្នកដាក់ពាក្យសុំ។ ប្រសិនអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនេះត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់តក្កករ នោះអត្តសញ្ញាណរបស់អ្នកតំណាងស្របច្បាប់នោះត្រូវដាក់នៅក្នុងពាក្យសុំផងដែរ។

ក្នុងករណីដែលតក្កករ ពុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ក្នុងប្រទេសកម្ពុជាទេ ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងស្របច្បាប់ដែលជាភ្នាក់ងារដែលមានទីលំនៅ និង កំពុងប្រកបវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា[11] និង ដែលបានបំពេញលក្ខខណ្ឌទាំងឡាយដែល បានកំណត់ដោយបញ្ញត្តិដោយឡែករបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។[12]

### ២.១.២ សេចក្តីអត្ថាធិប្បាយ

សេចក្តីអត្ថាធិប្បាយនៃតក្កកម្ម មានគោលដៅបញ្ជាក់អំពីព័ត៌មានទាក់ទងនិង បច្ចេកទេស ឬដំណើរការនៃការផលិត ដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតតក្កកម្មនោះ។ អត្ថន័យនៃសេចក្តីអធិប្បាយនៃតក្កកម្មនេះត្រូវបានកំណត់ដោយអនុក្រឹត្យ។ [13] ក្នុងសេចក្តីអធិប្បាយនេះ ត្រូវបញ្ជាក់អំពីឈ្មោះ ឬ ចំណងជើងនៃតក្កកម្ម និង បញ្ជាក់អំពីលក្ខណៈបច្ចេកទេស ដែលពាក់ព័ន្ធនឹងស្នាដៃក្នុងលក្ខខណ្ឌមួយដែលអាចយល់បានដោយមន្ត្រីទទួលបន្ទុកចុះបញ្ជី។សេចក្តីអធិប្បាយត្រូវពណ៌នាពីផលប្រយោជន៍នៃតក្កកម្ម ដែលអាចយកទៅផលិត និងប្រើប្រាស់បានក្នុងវិស័យឧស្សាហកម្ម ឬសិប្បកម្មណាមួយជាក់លាក់។

### ២.១.៣ សេចក្តីអះអាង

សេចក្តីអះអាង គឺជាការកំណត់ឱ្យបានច្បាស់លាស់អំពីចំណុចដែលចង់សុំឱ្យមានការពារដូច្នេះសេចក្តីអះអាងត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងភ្ជាប់មកជាមួយនូវគំនូសបង្ហាញនៃតក្កកម្មនោះ។ ក្នុងករណីសំណុំស្នើសុំអន្តរជាតិនោះមានសេចក្តីអះអាងច្រើនជាងមួយអ្នកដាក់ពាក្យសុំត្រូវ

[11] មាត្រា ១១៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

[12] ប្រការ ៣៣ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[13] ប្រការ ៧ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ដាក់លេខលំដាប់នៃសេចក្តីអះអាងនោះ។[14]

**២.១.៤ ខ្លឹមសារសង្ខេបនៃតក្កកម្ម**

ខ្លឹមសារសង្ខេបគឺជា សេចក្តីសង្ខេបអំពីព័ត៌មានបច្ចេកទេសរបស់តក្កកម្មក្នុងគោលបំណងពន្យល់ដោយសង្ខេបច្បាស់លាស់អំពីការបង្កើត និង ការប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសរបស់តក្កកម្មនោះ។

## ២.២. ការត្រួតពិនិត្យលិខិតស្នើសុំចុះបញ្ជី

ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវមានបញ្ជាក់អំពីជំពូកនៃតក្កកម្ម ដែលជាកម្មវត្ថុនៃកិច្ចការពារ ដោយអនុលោមតាមចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្ម ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងស្ត្រាសបួចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧១។

ការត្រួតពិនិត្យរបស់មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើឡើងជា ពីរតំណាក់កាល មុនពេលចេញប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំ ៖ ការពិនិត្យលើការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម និង ការត្រួតពិនិត្យយលំអិត (ពិនិត្យលក្ខណៈបច្ចេកទេសនៃតក្កកម្ម)។

**២.២.១ ការពិនិត្យលិខិតលើពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម**

នៅក្នុងចំណាត់ការនៃការត្រួតពិនិត្យនេះ យើងអាចហៅបានថា ជាការត្រួតពិនិត្យបឋម។ កម្មវត្ថុនៃការត្រួតពិនិត្យ បឋមនេះ គឺជាការត្រួតពិនិត្យ មើលលើទម្រង់នៃឯកសារដាក់ពាក្យសុំថាតើត្រូវបាន បំពេញតាមការកំណត់របស់ច្បាប់ និង មានព័ត៌មានគ្រប់គ្រាន់ដែរឬទេដែលរួមមានជាអាទិ៍[15] ៖

- លិខិតផ្ទេរសិទ្ធិជាតំណាងស្របច្បាប់ (ប្រសិនបើមានអ្នកតំណាង)
- ពាក្យស្នើសុំ
- ហត្ថលេខា
- គំរូនៃតក្កកម្ម
- សេចក្តីអធិប្បាយនៃតក្កកម្ម
- សេចក្តីអះអាងនៃសេចក្តីស្នើសុំ
- គំនូសបង្ហាញតក្កកម្ម
- ខ្លឹមសារសង្ខេបនៃតក្កកម្ម

[14] ប្រការ ៨ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[15] ប្រការ ២៤ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

- ឈ្មោះ អាសយដ្ឋាន និង លំនៅដ្ឋានរបស់តក្កករ ឬអ្នកតំណាង
- បានបង់ប្រាក់កម្រៃរដ្ឋបាលកំណត់។

**២.២.២ ការត្រួតពិនិត្យលំអិត**

ការត្រួតពិនិត្យលំអិត គឺជាការត្រួតពិនិត្យលើលក្ខខណ្ឌគ្រឹះនៃតក្កកម្ម ៖ ភាពថ្មីជំហាននៃការរកឃើញថ្មីនិងអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម។ តំណាក់កាលនេះមន្ត្រីកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យលើអត្ថន័យនៃតក្កកម្ម ដែលបានដាក់ពាក្យស្នើសុំមកនោះបានបំពេញលក្ខខណ្ឌនៃតក្កកម្មដែលអាចចុះបញ្ជីបានតាមច្បាប់ដែរឬទេ។ ប្រសិនបើតក្កកម្មដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីមិនបានបំពេញតាមលក្ខខណ្ឌណាមួយ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកមកដាក់ពាក្យសុំអោយបំពេញចំណុចខ្វះខាតនៃពាក្យសុំតាមច្បាប់។[16]

## ២.៣. ការសម្រេចលើប្រកាសនីយបត្រតក្កកម្ម

បើក្រោយពេលមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យលើខ្លឹមសារនៃសំណុំពាក្យស្នើសុំរួចហើយ ថាលក្ខខណ្ឌដែលតម្រូវ[17]ដូចមានចែងក្នុង មាត្រា ៣៥ និង ៣៦ មិនត្រូវបានបំពេញត្រឹមត្រូវទេ និងមិនបានធ្វើការកែតម្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីនឹងសម្រេចបដិសេធការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្ម (២.៣.១) ។ ផ្ទុយទៅវិញ បើពិនិត្យឃើញថាត្រឹមត្រូវរួចរាល់អស់ហើយនឹងសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មដល់អ្នកដាក់ពាក្យស្នើសុំ (២.៣.២) ។ រាល់សេចក្តីសម្រេចទាំងឡាយរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មនេះ សុទ្ធតែអាចធ្វើជាកម្មវត្ថុនៃការប្តឹងតវ៉ាដោយភាគីពាក់ព័ន្ធទៅតុលាការមាន សមត្ថកិច្ច ក្នុងរយៈពេល ៣ខែ ចាប់គិតពីថ្ងៃចេញសេចក្តីសម្រេចនោះមក។[18]

**២.៣.១ ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម**

ជាគោលការណ៍ ការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្ម ជូនដល់អ្នកដាក់ពាក្យសុំណាម្នាក់ត្រូវចាត់ទុកថាជាទណ្ឌកម្មខាងរដ្ឋបាលក្នុងករណី ដែលសំណុំនៃពាក្យសុំពុំគោរពនូវលក្ខខណ្ឌតម្រូវរបស់ច្បាប់។ មានមូលដ្ឋានពីរយ៉ាងដែលអាចនាំឲ្យមន្ត្រីកាន់កាប់បញ្ជាត្រូវតែធ្វើ ការបដិសេធ គឺ ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មមិនគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

---

[16] ប្រការ ២៥ នៃប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[17] មាត្រា ៣៥ និង ៣៦ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

[18] មាត្រា ១២៤ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

**ក.ការមិនគោរពលក្ខខណ្ឌគ្រឹះ**

បើមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យឃើញថាតក្កកម្មដែលស្នើសុំប្រកាសនីយបត្រតក្កកម្មនោះពុំបានបំពេញនូវលក្ខណៈវិនិច្ឆ័យតាមខ្លឹមសារនៃតក្កកម្មដែលបានតម្រូវទេនោះមន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធនូវពាក្យស្នើសុំចុះបញ្ជីជាដាច់ខាត [19] ដោយមិនអាចអនុញ្ញាតឲ្យមានការកែតម្រូវអ្វីឡើយ។ ដូចនេះកង្វះខាតនៃលក្ខខណ្ឌទាក់ទងនឹងខ្លឹមសាររបស់តក្កកម្មនេះក៏ជាមូលដ្ឋាននៃការបដិសេធដាច់ខាតនៅក្នុងផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ។

**ខ.ការមិនគោរពលក្ខខណ្ឌទម្រង់**

កាលណាមន្ត្រីកាន់កាប់បញ្ជីបានរកឃើញថា សំណុំលិខិតទាំងនោះពុំបានគោរពតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ទេនោះ មន្ត្រីកាន់កាប់បញ្ជីនឹងណែនាំឲ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវជាថ្មីឡើងវិញ។ ប៉ុន្តែប្រសិនបើសំណុំលិខិតទាំងនោះមិនត្រូវបានកែតម្រូវតាមការណែនាំទេមន្ត្រីកាន់កាប់បញ្ជីនឹងបដិសេធពាក្យស្នើសុំនោះចោលដោយចាត់ទុកថាដូចជាមិនបានដាក់ពាក្យស្នើសុំចុះបញ្ជី។[20]

**២.៣.២ ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម**

កាលបើទាំងលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ត្រូវបានគោរពតាមគ្រប់គ្រាន់អស់ហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មជូនដល់អ្នកស្នើសុំ។ នៅក្នុងករណីនេះ ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មដល់អ្នកដាក់ពាក្យស្នើសុំតម្រូវឲ្យមន្ត្រីកាន់កាប់បញ្ជីត្រូវចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និង ផ្តល់ប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ជូនដល់អ្នកដាក់ពាក្យស្នើសុំនោះ។ [21] បន្ទាប់មកមន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ជូននោះទៅក្នុងបញ្ជីសម្រាប់ប្រកាសនីយបត្រតក្កកម្ម។ សេចក្តីចម្លងនៃប្រកាសនីយបត្រតក្កកម្មនេះអាចនឹងត្រូវបានផ្តល់ជូនទៅបុគ្គលណាម្នាក់ (សាធារណជន) ដែលមានប្រយោជន៍ពាក់ព័ន្ធក្រោមរូបភាពជាការជាវពីរដ្ឋទៅតាមតម្លៃដែលបានកំណត់ ។

ជាងនេះទៀត ក្រោយទទួលបានប្រកាសនីយបត្រតក្កកម្ម ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មអាចស្នើសុំឲ្យមន្ត្រីកាន់កាប់បញ្ជីធ្វើការកែសម្រួលនៅក្នុងអត្ថបទ ឬ គំនូសបង្ហាញរបស់ប្រកាសនីយបត្រតក្កកម្មនោះ ដើម្បីកំណត់ពីទំហំនៃការការពារប្រកាសនីយបត្រតក្កកម្មនោះបានរៀវលែងតែការកែសម្រួលនោះ នាំឲ្យប្រែប្រួលលើខ្លឹមសារ ដូចបានសរសេរនៅក្នុងសំណុំលិខិតស្នើសុំ

[19] ប្រការ ២៦ ចំណុច២ នៃប្រកាសលេខ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[20] មាត្រា ៣៤ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

[21] មាត្រា ៣៩ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

ពីដំបូង ដែលសម្រាប់ ធ្វើជាមូលដ្ឋាន ឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ។[22]

ពុំមានមាត្រាណាមួយ នៃច្បាប់ដែលតម្រូវឲ្យមន្ត្រីកាន់កាប់បញ្ជី មានកាតព្វកិច្ច ចុះផ្សាយនូវពាក្យស្នើសុំនោះ ដើម្បីអាចអនុញ្ញាតឲ្យតតីយជន មានប្រយោជន៍ចូលខ្លួនមក អះអាងសិទ្ធិប្រឆាំងនឹងការសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនោះសោះឡើយថ្វីត្បិតតែ មាត្រា ១១៩ នៃច្បាប់នេះបានតម្រូវឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះផ្សាយនៅក្នុងព្រឹត្តិប័ត្តផ្លូវការនូវរាល់ព័ត៌មានដែលត្រូវចុះផ្សាយជាសាធារណៈក៏ដោយ។

[22] មាត្រា ៤០ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

# ជំពូកទី៣ នីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

នីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញា PCT ត្រូវបានបែងចែកជាពីរកម្រិត គឺនៅថ្នាក់អន្តរជាតិ និង នៅថ្នាក់ជាតិ។ នៅក្នុងថ្នាក់អន្តរជាតិ នីតិវិធីនៃការចុះបញ្ជីត្រូវបានចែកជា ៥ ដំណាក់កាល ដោយនីតិវិធីចំនួន ៣ ជានីតិវិធីតម្រូវ គឺ ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ (៣.១) ការស្រាវជ្រាវអន្តរជាតិរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ (៣.២) និង ការបោះផ្សាយជាអន្តរជាតិ (៣.៣) ដែលជានីតិវិធីតម្រូវចាំបាច់សម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិទាំងអស់។ ចំនែកនីតិវិធី ០២ ផ្សេងទៀត គឺជានីតិវិធីជម្រើសរបស់អ្នកដាក់ពាក្យសុំក្នុងការពិចារណាថាតើគួរអនុវត្ត ឬ មិនអនុវត្ត រួមមាន ការស្រាវជ្រាវអន្តរជាតិបន្ថែម (៣.៤) និង ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិ (៣.៥)។ បន្ទាប់ពីបញ្ចប់នីតិវិធីនៃការចុះបញ្ជីនៅកម្រិតអន្តរជាតិ ដំណាក់កាលបន្ទាប់គឺបន្តដល់ថ្នាក់ អន្តរជាតិនៃប្រទេសនីមួយៗ ដែលអ្នកដាក់ពាក្យសុំមានបំណងចង់ឱ្យមានការពារ ដែលតម្រូវឱ្យបំពេញនូវលក្ខខណ្ឌចំបាច់មួយចំនួនដូចដែលបានកំណត់ដោយសន្ធិសញ្ញានេះ (៣.៦)។

## ៣.១. ការដាក់ពាក្យស្នើសុំអន្តរជាតិ

### ៣.១.១ ពាក្យស្នើសុំអន្តរជាតិ

សំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវដាក់នៅការិយាល័យទទួល ផ្អែកតាមមាត្រា១០ នៃសន្ធិសញ្ញាហើយការិយាល័យទទួលនោះនឹងធ្វើការពិនិត្យ និង ដំណើរការចំពោះសំណុំលិខិតស្នើសុំអន្តរជាតិនោះបន្ត។ ការិយាល័យទទួលសំណុំលិខិតស្នើសុំអន្តរជាតិ អាចជាការិយាល័យចុះបញ្ជីជាតិ ឬ ការិយាល័យចុះបញ្ជីតំបន់ ឬ ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយសំណុំលិខិតស្នើសុំអន្តរជាតិនោះ ត្រូវគោរពតាមលក្ខខណ្ឌដូចនឹងលក្ខខណ្ឌនៃ សំណុំលិខិតស្នើប្រកាសនីយបត្រតក្កកម្មជាតិផងដែរ ពោលគឺត្រូវមានពាក្យសុំ សេចក្តីអត្ថាធិប្បាយ អំពីតក្កកម្ម សេចក្តីអះអាង ខ្លឹមសារសង្ខេប និង គំនូសបង្ហាញ (ក្នុងករណីបើមានគំនូសបង្ហាញ)។

**ក. ពាក្យសុំ**

ដើម្បីដាក់សំណុំលិខិតស្នើសុំអន្តរជាតិ អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទតាមទម្រង់ដែលបានកំណត់ជាអន្តរជាតិសម្រាប់សមាជិក PCT (ទម្រង់ PCT/RO/101) ដែលទម្រង់នៃពាក្យសុំនេះ តម្រូវឱ្យអ្នកស្នើសុំត្រូវបង្ហាញព័ត៌មានអំពីសំណុំលិខិតស្នើសុំជាអន្តរជាតិលម្អិត។ ជាគោល

ការណ៍ ពាក្យសុំត្រូវមានព័ត៌មានចាំបាច់ដូចខាងក្រោម[23]៖

- ឈ្មោះ និង ទិន្នន័យផ្សេងទៀតពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំ និង ភ្នាក់ងារ ឬ អ្នកតំណាង (ប្រសិនបើមាន) ដូចជាអំពីអាសយដ្ឋាន សញ្ជាតិ ប្រទេស
- ចំណងជើងរបស់តក្កកម្មខ្លី និង ច្បាស់លាស់ (គួរតែមានចាប់ពីរពាក្យទៅប្រាំពីរពាក្យ)
- ព្រមទាំងឈ្មោះ និងទិន្នន័យផ្សេងទៀត ពាក់ព័ន្ធនឹងតក្កកម្ម ដែលច្បាប់ជាតិរបស់រដ្ឋជម្រើសរើស តម្រូវឱ្យបញ្ជាក់នៅពេលសំណុំលិខិតស្នើសុំជាតិ។[24]

**ខ. សេចក្តីអត្ថាធិប្បាយ**

សេចក្តីអធិប្បាយ គឺជាការពន្យល់អំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និង ពេញលេញដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។ សេចក្តីអធិប្បាយអំពីតក្កកម្មត្រូវមានចំណុចសំខាន់ៗដូចខាងក្រោម៖

- មានចំណងជើងតក្កកម្ម និង អំពីជំនាញក្នុងវិស័យ ដែលយកទៅប្រើប្រាស់
- មានព័ត៌មានទូទៅអំពីបច្ចេកវិទ្យាពាក់ព័ន្ធនឹងតក្កកម្ម
- ពន្យល់អំពីបញ្ហាដែលកំពុងជួបប្រទះហើយបញ្ជាក់ថា តក្កកម្មនេះបានដោះស្រាយបញ្ហាកំពុងជួបប្រទះ និង ឥទ្ធិពលជាវិជ្ជមានដល់សង្គមពន្យល់សង្ខេបអំពីបច្ចេកទេសនៃការប្រើប្រាស់តក្កកម្ម ដែលល្អជាងគេ
- បញ្ជាក់ថាតក្កកម្មអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម។[25]

**គ. សេចក្តីអះអាង**

សេចក្តីអះអាង គឺជាការកំណត់ឱ្យបានច្បាស់លាស់ អំពីចំណុចដែលចង់សុំឱ្យមានការពារ ដូច្នេះសេចក្តីអះអាងត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់និងភ្ជាប់មកជាមួយនូវគំនូសបង្ហាញនៃតក្កកម្មនោះ។ ក្នុងករណី សំណុំស្នើសុំអន្តរជាតិនោះមានសេចក្តីអះអាងច្រើនជាងមួយអ្នកដាក់ពាក្យសុំត្រូវដាក់លេខជាលំដាប់នៃសេចក្តីអះអាងនោះ។

**ឃ. គំនូសបង្ហាញ**

សំណុំលិខិតស្នើសុំអន្តរជាតិ ចាំបាច់ត្រូវមានគំនូសបង្ហាញដើម្បីពន្យល់អំពីតក្កកម្ម ដែលបានដាក់ពាក្យស្នើសុំនោះ។ ជាឧទាហរណ៍ ប្រសិនបើតក្កកម្មពាក់ព័ន្ធនឹងប្រព័ន្ធមេកានិចនិង អគ្គិសនី

[23] មាត្រា ៤ នៃសន្ធិសញ្ញា PCTសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[24] មាត្រា ៤(១), ៤៣, ៤៤, ៤៥ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៣, ៤ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[25] មាត្រា ៥ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

គំនូសបង្ហាញចាំបាច់ត្រូវមាននៅក្នុងសំណុំលិខិតស្នើសុំ។ នៅក្នុងគំនូសបង្ហាញនេះ អ្នកដាក់ពាក្យស្នើសុំត្រូវមានដាក់លេខនិងពន្យល់អំពីតួនាទីនិង ដំណើរការរបស់តក្កកម្មឱ្យបានច្បាស់លាស់។[26]

**ខ. ខ្លឹមសារសង្ខេបនៃតក្កកម្ម**

ខ្លឹមសារសង្ខេប គឺជាសេចក្តីសង្ខេបអំពីព័ត៌មានបច្ចេកទេស របស់តក្កកម្មក្នុងគោលបំណងពន្យល់ដោយសង្ខេបច្បាស់លាស់អំពីការបង្កើតនិង ការប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសរបស់តក្កកម្មនោះ។ ខ្លឹមសារសង្ខេបត្រូវត្រូវសរសេរបានពី ៥០ ទៅ ១៥០ពាក្យ ជាភាសាអង់គ្លេស។

**៣.១.២ ការដាក់ពាក្យស្នើសុំអន្តរជាតិ**

ដូចបានរៀបរាប់នៅខាងលើ ដើម្បីទទួលបានការការពារអ្នកដាក់ពាក្យសុំត្រូវដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅការិយាល័យទទួលដែលការិយាល័យទទួលនោះ គឺអាចការិយាល័យថ្នាក់ជាតិរបស់រដ្ឋដែលជាសមាជិកណាមួយ ការិយាល័យកម្រិតតំបន់ ឬ ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ក្នុងករណីអ្នកដាក់ពាក្យសុំជាពលរដ្ឋនៃប្រទេសដែលជាសមាជិកសន្ធិសញ្ញាតក្កកម្មថ្នាក់តំបន់ ដូចជាពិធីសារ ARIPO Harare អនុសញ្ញាតក្កកម្មអាស៊ី-អឺរ៉ុប អនុញ្ញាតក្កកម្មអឺរ៉ុប ឬ កិច្ចព្រមព្រៀង OAPI Bangui អ្នកដាក់ពាក្យសុំនោះអាចដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅការិយាល័យទទួលថ្នាក់តំបន់នោះបាន។

**ក. ការិយាល័យទទួល**

ការិយាល័យទទួល គឺជាការិយាល័យដែលមានសមត្ថភាពទទួលសំណុំលិខិតស្នើសុំចុះបញ្ជីក្រោមនីតិវិធីនៃសន្ធិសញ្ញា PCT ទទួលថវិការពាក់ព័ន្ធនឹងការចុះបញ្ជីនិង ត្រួតពិនិត្យលើសំណុំលិខិតស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ PCT ដើម្បីទទួលបានការចុះបញ្ជីជាអន្តរ ជាតិ។[27]

ផ្អែកតាមមាត្រា ១៩ នៃវិធានស្ថិតក្រោមសន្ធិសញ្ញា PCT បានកំណត់បានការិយាល័យទទួលគឺអាចជា៖

- ការិយាល័យចុះបញ្ជីជាតិ នៃប្រទេសហត្ថលេខី
- ប្រទេសហត្ថលេខីមួយនៃសន្ធិសញ្ញា PCT បានព្រមព្រៀងជាមួយនឹងប្រទេសហត្ថលេខីសន្ធិសញ្ញា PCT ឬ អង្គការអន្តររដ្ឋាភិបាលមួយថា ការិយាល័យចុះបញ្ជីជាតិរបស់ខ្លួនគឺជាការិយាល័យទទួលជំនួសរដ្ឋហត្ថលេខី ឬ អង្គការអន្តររដ្ឋាភិបាល ដែលស្នើសុំនោះ
- ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

[26] មាត្រា ៧ និង ៨ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[27] មាត្រា ១០ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

### ខ. ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ

ដើម្បីពិនិត្យសំណុំលិខិតស្នើសុំ ការិយាល័យទទួលត្រូវពិនិត្យមើលលើចំណុចពីរសំខាន់ ទី១ ពិនិត្យលើលក្ខខណ្ឌដើម្បីទទួលកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ (មាត្រា ១១(១)) និង ពិនិត្យលើភាពខ្វះចន្លោះក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ (មាត្រា១៤) ។

ផ្អែកតាមមាត្រា ១១ (១) ការិយាល័យទទួល ត្រូវចុះកាលបរិច្ឆេទនៃការសុំចុះបញ្ជីលើសំណុំលិខិតស្នើសុំអន្តរជាតិ នៅពេលសំណុំលិខិតនេះបានបំពេញតាមលក្ខខណ្ឌខាងក្រោមត្រឹមត្រូវ៖

- អ្នកដាក់ពាក្យសុំ មានអាសយដ្ឋាន ឬ មានសញ្ជាតិ នៃប្រទេសដែលជាសមាជិកសន្ធិសញ្ញា PCT
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវធ្វើជាភាសាដែលបានកំណត់
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវមានយ៉ាងហោចណាស់នូវធាតុទាំងឡាយដូចតទៅ៖
    - ការបញ្ជាក់ថា សំណុំលិខិតស្នើសុំនេះត្រូវបានគ្រោងទុកជាសំណុំលិខិតស្នើសុំអន្តរជាតិ
    - មានការជ្រើសរើសយ៉ាងហោចណាស់ក៏មានរដ្ឋហត្ថលេខីមួយ
    - មានឈ្មោះរបស់អ្នកដាក់ពាក្យសុំយ៉ាងតិចម្នាក់
    - មានផ្នែកមួយ នៃសេចក្តីអធិប្បាយ
    - និងមានផ្នែកមួយនៃសេចក្តីអះអាង។

ករណីបើសំណុំលិខិតស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌខាងលើនេះ ការិយាល័យទទួលនឹងអញ្ជើញអ្នកដាក់ពាក្យសុំឱ្យមកកែតម្រូវក្នុងរយៈពេល ០២ខែបន្ទាប់ពីចេញលិខិតអញ្ជើញឲ្យធ្វើការកែតម្រូវ ហើយការកំណត់កាលបរិច្ឆេទនៃការសុំចុះបញ្ជីអន្តរជាតិនឹង ត្រូវផ្តល់អោយនៅពេលអ្នកដាក់ពាក្យសុំបានបំពេញសំណុំបែបបទត្រឹមត្រូវ និង ចប់សព្វគ្រប់តាមលក្ខខណ្ឌដែលបានកំណត់។

បន្ទាប់ពីបានពិនិត្យលើចំណុចដូចមានកំណត់ក្នុងមាត្រា ១១ ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិក៏ត្រូវផ្អែកតាមមាត្រា ១៤ ពោលការិយាល័យទទួលក៏នឹងត្រូវពិនិត្យលើភាពខ្វះចន្លោះលើសំណុំលិខិតស្នើសុំអន្តរជាតិដូចខាងក្រោម៖

- មិនមានចុះហត្ថលេខា
- មិនមានការបញ្ជាក់ដូចបានកំនត់ពាក់ព័ន្ធអ្នកដាក់ពាក្យសុំ
- មិនមានចំណងជើងតក្កកម្ម
- មិនមានខ្លឹមសារសង្ខេប

- មិនបានបំពេញតាមការកំណត់ក្នុងបទបញ្ជា ព្រមទាំងការតម្រូវផ្នែករូបសាស្ត្រ។

ក្នុងករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌខាងលើ ការិយាល័យទទួលនឹងអញ្ជើញអ្នកដាក់ពាក្យសុំមកកែតម្រូវក្នុងរយៈពេលកំណត់ តែការឱ្យមកកែតម្រូវនេះនឹងមិនប៉ះពាល់ដល់កាលបរិច្ឆេទនៃចុះបញ្ជីអន្តរជាតិនោះទេ។ ក៏ប៉ុន្តែក្នុងករណីមានការខកខានមិនបានកែតម្រូវក្នុងរយៈពេលកំណត់ទេនោះ សំណុំលិខិតស្នើសុំអន្តរជាតិនោះត្រូវចាត់ទុកថា បានដកយ ពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT។

ជាចុងក្រោយនៅពេលទទួលបានកាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ការិយាល័យទទួលនឹងធ្វើសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ និង លេខសំណុំលិខិតស្នើសុំអន្តរជាតិទៅឱ្យអ្នកដាក់ពាក្យសុំបានដឹង។

**គ. ការទាមទារអាទិភាព**

សំណុំលិខិតស្នើសុំអន្តរជាតិអាចមានការទាមទារអាទិភាពចំពោះតក្កកម្មរបស់ខ្លួនដែលទទួលបានការពារកន្លងមក។ដូច្នេះអ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាពដោយបញ្ជាក់ឱ្យច្បាស់អំពីប្រទេសដែលបានចុះបញ្ជីអំពីកាលបរិច្ឆេទនិងលេខនៃសំណុំលិខិតនិងអំពីការិយាល័យទទួល។

អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាពក្នុងរយៈពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចុះលេខលើសំណុំលិខិតលើកដំបូង។ ករណីដែលអ្នកដាក់ពាក្យសុំមិនដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ក្នុងរយៈពេល ១២ខែទេ អ្នកដាក់ពាក្យសុំអាចស្នើសុំទាមទារឲ្យផ្តល់អាទិភាពម្តងទៀត ក្នុងរយៈពេល ០២ខែ គិតចាប់ពីកាល បរិច្ឆេទនៃការផុតកំណត់រយៈពេលទាមទារអាទិភាព។ ដូច្នេះអ្នកដាក់ពាក្យសុំតម្រូវឲ្យធ្វើសេចក្តីថ្លែងការណ៍ ឬ ភស្តុតាងដើម្បីបញ្ជាក់ពីមូលហេតុដែលមិនបានដាក់សំណុំលិខិតស្នើសុំអន្តរជាតិទាន់ពេលវេលាកំណត់។[28]

**ឃ. លក្ខខណ្ឌទទួលបានសិទ្ធិអាទិភាព**

អ្នកដាក់ពាក្យសុំត្រូវប្រគល់សំណុំឯកសារស្នើសុំដំបូង ទៅការិយាល័យទទួលក្នុងរយៈពេល ១៦ខែ គិតចាប់ពីថ្ងៃទទួលបានសិទ្ធិអាទិភាពដំបូង។

ប្រសិនបើឯកសារទាមទារសិទ្ធិអាទិភាពចេញដោយការិយាល័យទទួល ដូច្នេះអ្នកដាក់ពាក្យសុំត្រូវស្នើការិយាល័យទទួលរៀបចំឯកសារទាមទារសិទ្ធិអាទិភាព និង បញ្ជូនឯកសារទាំងនោះទៅការិយាល័យអន្តរជាតិ ក្នុងរយៈពេល ១៦ខែ និងមុនការបោះផ្សាយជាអន្តរជាតិ។

**ង.ភាសាប្រើប្រាស់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ**

[28] មាត្រា ៨ (២ខ) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ភាសាដែលប្រើប្រាស់ជាផ្លូវការសម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវតែជាៈ

- ភាសាដែលទទួលស្គាល់ដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ
- ភាសាសម្រាប់បោះពុម្ពផ្សាយ មានដូចជា ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង អាល្លឺម៉ង់ ជប៉ុន កូរ៉េ ព័រទុយហ្គាល់ ឬ អេស្ប៉ាញ ឬ
- ភាសា ដែលទទួលស្គាល់ដោយការិយាល័យទទួល។

ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិមិនបានប្រើប្រាស់ភាសា ដែលបានកំណត់តាមលក្ខខណ្ឌខាងលើ អ្នកដាក់ពាក្យសុំត្រូវតែបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាដែលកំណត់ក្នុងរយៈពេល០១ខែ បន្ទាប់ពីការិយាល័យទទួលបានទទួលនូវសំណុំលិខិតស្នើសុំអន្តរជាតិនោះ។ ប្រសិនមិនបកប្រែទាន់ពេលវេលាកំណត់នោះទេ ការិយាល័យទទួលនឹងប្រកាសថាសំណុំលិខិតស្នើសុំអន្តរជាតិនោះ នឹងដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT។

**ច. ការបង់កម្រៃ**

អ្នកដាក់ពាក្យ ត្រូវបង់កម្រៃមួយចំនួនដើម្បីចុះបញ្ជីអន្តរជាតិទៅការិយាល័យទទួលដូចខាងក្រោមៈ

- កម្រៃបញ្ជូនឯកសារ
- កម្រៃចុះបញ្ជីអន្តរជាតិ
- កម្រៃស្រាវជ្រាវ
- កម្រៃក្រដាសបន្ថែម
- កម្រៃឯកសារទាមទារសិទ្ធិអាទិភាព
- កម្រៃដែលបង់ប្រាក់យឺត
- កម្រៃនៃការកែសម្រួលឯកសារយឺត
- កម្រៃសម្រាប់ទាមទារសិទ្ធិអាទិភាពម្តងទៀត
- កម្រៃឯកសារថតចម្លងនានា។

## ៣.២ ការស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ

នៅក្នុងដំណាក់កាលនេះបន្ទាប់ពីទទួលបានច្បាប់ចម្លងសម្រាប់ការស្រាវជ្រាវពីការិយាល័យទទួល អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងអនុវត្តនីតិវិធីចំនួន ០៣ សំខាន់ គឺ ការស្រាវជ្រាវអន្តរជាតិ (៣.២.១) បន្ទាប់មកត្រូវរៀបចំរបាយការណ៍ស្រាវជ្រាវអន្តរជាតិ (៣.២.២) និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ (៣.២.៣) ។

ការិយាល័យទទួលត្រូវជ្រើសរើសអាជ្ញាធរស្រាវជ្រាវអន្តរជាតិយ៉ាងតិចមួយ ដើម្បីស្រាវជ្រាវ

ជាអន្តរជាតិ និង ចេញរបាយការណ៍ស្រាវជ្រាវដល់អ្នកដាក់ពាក្យសុំក្នុងរយៈពេល ១៦ខែ គិតចាប់កាលបរិច្ឆេទទាមទារអាទិភាព។ អ្នកដាក់ពាក្យសុំនឹងទទួលបានរបាយការណ៍ស្រាវជ្រាវជាអន្តរជាតិពីអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ដែលទទួលស្គាល់ដោយការិយាល័យទទួល ដែលបច្ចុប្បន្នអាជ្ញាធរស្រាវជ្រាវអន្តរជាតិទាំងនោះមានចំនួន ១៩ រួមមានៈ

១. ការិយាល័យតក្កកម្មអូស្ត្រាលី

២. ការិយាល័យតក្កកម្មអូទ្រីស

៣. វិទ្យាស្ថានជាតិកម្មសិទ្ធិឧស្សាហកម្មប្រេស៊ីល

៤. ការិយាល័យ កម្មសិទ្ធិបញ្ញាកាណាដា

៥.ការិយាល័យតក្កកម្មអេហ្ស៊ីប

៦.ការិយាល័យតក្កកម្មអឺរ៉ុប

៧. សេវាកម្ម សហពន្ធរុស្ស៊ីសម្រាប់កម្មសិទ្ធិបញ្ញា

៨.ការិយាល័យតក្កកម្មឥណ្ឌា

៩.ការិយាល័យកម្មសិទ្ធិបញ្ញាសិង្ហបុរី

១០.ការិយាល័យតក្កកម្មអីស្រាអែល

១១.ប្រកាសនីយបត្រតក្កកម្មជប៉ុន

១២.ការិយាល័យ កម្មសិទ្ធិបញ្ញាកូរ៉េ

១៣.ក្រុមប្រឹក្សាជាតិតក្កកម្ម និងចុះបញ្ជីហ្វាំងឡង់

១៤.វិទ្យាស្ថានជាតិកម្មសិទ្ធិ ឧស្សាហកម្មឈីលី

១៥.វិទ្យាស្ថានប្រកាសនីយបត្រតក្កកម្មណ័រឌិក

១៦.ការិយាល័យតក្កកម្ម និង ម៉ាកអេស្ប៉ាញ

១៧.ការិយាល័យកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋប្រជាមានិតចិន

១៨.ការិយាល័យ តក្កកម្មស៊ុយអ៊ែត និងចុះបញ្ជី និង

១៩. ការិយាល័យតក្កកម្ម និង ម៉ាកសហរដ្ឋអាមេរិក។

### ៣.២.១ ស្រាវជ្រាវអន្តរជាតិ

គោលបំណងនៃការស្រាវជ្រាវអន្តរជាតិគឺដើម្បីស្វែងរកស្នាដៃមុន (prior art) ដែលធ្លាប់បានចុះបញ្ជីពីមុនមក ដើម្បីធានាថាតក្កកម្មកំពុងស្នើសុំអោយមានការការពារ គឺថ្មីមានជំហាននៃការឃើញថ្មី។ ដូច្នេះ អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវខំប្រឹងប្រែងស្វែងរកស្នាដៃមុន ដែលពាក់ព័ន្ធឱ្យ

បានច្រើនតាមលទ្ធភាពខ្លួន (is facilities permit)។[29]

ការស្រាវជ្រាវអន្តរជាតិ គឺផ្អែកលើឯកសារសំខាន់មួយដែលមានឈ្មោះថា "PCT minimum documentation" ដែលជាប្រភេទឯកសារចងក្រងការបោះពុម្ពផ្សាយអំពីតក្កកម្មដែលចេញដោយប្រទេសចិនចាប់ពីឆ្នាំ ១៩២០ ប្រទេសបារាំង ប្រទេសអាឡឺម៉ង់ ចាប់ពីឆ្នាំ ១៩៤៥ ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសរុស្ស៊ី ប្រទេសស្វីស ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អង្គការកម្មសិទ្ធិ បញ្ញាទ្វីបអាហ្វ្រិក អង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិក និង ការិយាល័យចុះបញ្ជីតក្កកម្មអឺរ៉ូ អាស៊ី និងនៅអឺរ៉ុប។ "PCT minimum documentation" ក៏មានចងក្រងនូវសៀវភៅផ្សព្វផ្សាយអំពី ពាក្យសុំចុះបញ្ជីតក្កកម្ម ដែលចេញដោយការិយាល័យអន្តរជាតិ និង ដោយប្រទេសដទៃទៀតចាប់ពី ឆ្នាំ១៩២០ មកផងដែរ។[30]

**ក. កម្មវត្ថុមិនស្ថិតក្នុងការស្រាវជ្រាវ**

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងមិនស្រាវជ្រាវនោះទេករណីតក្កកម្ម ដែលបានស្នើសុំនោះស្ថិតក្នុងប្រភេទទាំង ៦ ដូចខាងក្រោមៈ

- ទ្រឹស្តីវិទ្យាសាស្ត្រ និង វិធីសាស្ត្រគណិតវិទ្យា
- រុក្ខជាតិ ឬ សត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មរុក្ខជាតិ ឬ សត្វ
- គម្រោងការ ក្បួន ឬ វិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬ សម្រាប់លេងល្បែងកំសាន្ត
- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬ សត្វ ដោយការវះកាត់ ឬ ដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្តលើរាងកាយមនុស្ស ឬសត្វ
- បទបង្ហាញនៃព័ត៌មានដ៏កម្រ និង
- កម្មវិធីកុំព្យូទ័រ

**ខ. ការរួមបញ្ចូលនៃតក្កកម្ម**

អាជ្ញាធរស្រាវជ្រាវអន្តរជាតិ នឹងពិនិត្យលើសំណុំលិខិតស្នើសុំអន្តរជាតិ ថាតើបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលនៃតក្កកម្ម (Unity of Invention) ។ ការរួមបញ្ចូលគ្នានៃតក្កកម្ម គឺសំដៅថាតើ សំណុំលិខិតស្នើសុំអន្តរជាតិនោះមានតក្កកម្ម ឬ ក្រុមនៃតក្កកម្មដែលមានបច្ចេកទេស

[29] មាត្រា ១៥ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[30] មាត្រា ១៥ (ក) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិនិង ប្រការ ៣៤.១ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ប្រហាក់ប្រហែលគ្នាដើម្បីបង្ហាញថាមានជំហានបង្កើតថ្មី។

ករណីដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិរកឃើញថាខ្វះការរួមបញ្ចូលនៃតក្កកម្ម អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវអញ្ជើញអ្នកដាក់ពាក្យសុំឱ្យបង់កម្រៃបន្ថែមចំពោះ ការស្រាវស្រាវបន្ថែមតក្កកម្មនោះក្នុងរយៈពេល ០១ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតអញ្ជើញ។ របាយការណ៍ស្រាវជ្រាវអន្តរជាតិនឹងមិនត្រូវបានរៀបចំ ល្គឹកណាការបង់កម្រៃស្រាវជ្រាវ និង កម្រៃស្រាវជ្រាវបន្ថែមមិនត្រូវបានបង់ចប់សព្វគ្រប់។[31]

### ៣.២.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិ

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងចេញរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ក្នុងរយៈពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទបានទទួលច្បាប់ចម្លងសម្រាប់ស្រាវជ្រាវពីការិយាល័យទទួល ឬ នៅក្នុងរយៈពេល ០៩ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ របាយការណ៍នេះ នឹងបង្ហាញអំពីឯកសារគាំទ្រតក្កកម្មពាក់ព័ន្ធ ចំណាត់ថ្នាក់ តក្កកម្មស្របតាមចំណាត់ថ្នាក់តក្កកម្មអន្តរជាតិ (International Patent Classification) និង ការបញ្ជាក់អំពីប្រភេទនៃការស្រាវជ្រាវ (Field of Search) និង ប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវបាន (Electronic Data)។ គួរបញ្ជាក់ថា នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិមិនបង្ហាញទស្សនៈ ហេតុផល ឬ ការពន្យល់ណាមួយទៅលើលទ្ធផលនៃការស្រាវជ្រាវនោះទេ។[32]

### ៣.២.៣ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ

នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិនោះ អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរជាបឋម ក៏ប៉ុន្តែមិនចងកាតព្វកិច្ច ដោយវាយតម្លៃលើលក្ខខណ្ឌចំនួន បី គឺ ១.អំពីភាពថ្មី ២.អំពីភាពមានជំហាននៃការរកឃើញថ្មី និង ៣.អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ឬសិប្បកម្មនៃតក្កកម្មនោះ។

ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរនេះត្រូវសរសេរភាសាដូច នឹងភាសារបស់របាយការស្រាវជ្រាវអន្តរជាតិ ហើយត្រូវផ្ញើទៅអ្នកដាក់ពាក្យសុំ និង ការិយាល័យទទួល ព្រមជាមួយនឹងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ។ ទាំងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ត្រូវធ្វើក្នុងរយៈពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទទួលច្បាប់ចម្លងសម្រាប់

[31] មាត្រា ១៧ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ១៣, ៤០ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[32] មាត្រា ១៨ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៤២, ៤៣ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ស្រាវជ្រាវ ឬ ក្នុងរយៈពេល ០៩ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ក៏អាចរកបានតាមប្រព័ន្ធ PATENTSCOP[33] នៅពេលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានបោះផ្សាយ។[34]

### ក. ការឆ្លើយតបនឹងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ

ទោះជាក្នុងបទប្បញ្ញត្តិនៃ PCT មិនបានចែងកំណត់ជាក់លាក់អនុញ្ញាតអ្នកដាក់ពាក្យសុំអាចឆ្លើយតបនឹងការផ្តល់យោបល់ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែងអ្នកដាក់ពាក្យសុំអាចឆ្លើយតបនឹងការផ្តល់យោបល់នោះបាន។ ការឆ្លើយតបមិនផ្លូវការនោះត្រូវផ្ញើរទៅការិយាល័យអន្តរជាតិ ពោលគឺមិនមែនផ្ញើទៅអាជ្ញាធរស្រាវជ្រាវនោះទេ។ រាល់ការឆ្លើយតបទាំងនោះ នឹងត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធ PATENTSCOPE ដោយការិយាល័យអន្តរជាតិ។

### ខ.ការកែសម្រួលការអះអាងនៅចំពោះមុខការិយាល័យអន្តរជាតិ

បន្ទាប់ពីបានទទួលរបាយការណ៍ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរស្រាវជ្រាវ អ្នកដាក់ពាក្យសុំអាចកែសម្រួលការអះអាងរបស់ខ្លួនបាន ផ្អែកតាមនីតិវិធីនៃសន្ធិសញ្ញា PCT។ ក៏ប៉ុន្តែករណីដែលអ្នកដាក់ពាក្យសុំបានដាក់ការទាមទារការពិនិត្យជំហាន ដំបូងអន្តរជាតិ អ្នកដាក់ពាក្យសុំមានឱកាសកែសម្រួលការអះអាងរបស់ខ្លួនម្តងទៀត។ ជាមួយគ្នានោះ អ្នកដាក់ពាក្យសុំអាចដាក់សេចក្តីថ្លែងបញ្ជាក់សង្ខេប ដែលមាននៅក្នុងលើសេចក្តីអធិប្បាយនិង គំនូសបង្ហាញ។ ការកែសម្រួលនោះ មិនត្រូវឲ្យហួសពីការបញ្ចេញឲ្យដឹងក្នុងសំណុំលិខិតស្នើសុំអន្តជាតិដែលបានដាក់ពីដំបូងនោះទេ។

ផ្អែកតាមមាត្រា ១៩ នៃសន្ធិសញ្ញា PCT រយៈពេលនៃការកែសម្រួលជាធម្មតាមិនលើសពី ០២ខែ គិតចាប់ពីកាលបរិច្ឆេទនៃបញ្ជូនរបាយការណ៍ និង ការផ្តល់យោបល់ជាលាយលក្ខណ៍ពីអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេឬ ក្នុងរយៈពេល ១៦ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទារអាទិភាព។ ករណីចង់មានការកែសម្រួលនេះត្រូវដាក់ដោយផ្ទាល់នៅការិយាល័យអន្តរជាតិមិនមែននៅអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេ។

---

[33] មាត្រា ១៨ (១) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៤២, ៤៣, ៤៤ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[34] គឺជាសេវាកម្មស្រាវជ្រាវរបស់ WIPO ដែលអនុញ្ញាតឲ្យចូលមើលព័ត៌មានបច្ចេកទេសរបស់សំណុំលិខិតស្នើសុំអន្តរជាតិដែលបានចុះផ្សាយកន្លងមក

### គ.ទំនាក់ទំនងរវាងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ និងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ

ករណីអ្នកដាក់ពាក្យសុំមិនដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ នោះការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ នឹងប្រែក្លាយជារបាយការណ៍ជំហានដំបូងអន្តរជាតិ ស្តីអំពីភាពទទួលបានប្រកាសនីយបត្រតក្កកម្ម ដែលនឹងចេញដោយ ការិយាល័យអន្តរជាតិ ហើយនឹងត្រូវផ្ញើទៅគ្រប់ការិយាល័យជ្រើសរើសតាំង។ របាយការណ៍ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិស្តីអំពី ភាពទទួលបានប្រកាសនីយបត្រតក្កកម្មនឹងផ្សព្វផ្សាយនៅប្រព័ន្ធ PATENTSCOPE ដល់សាធារណៈជន។

ប្រសិនបើមានការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ អាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិនឹងប្រើប្រាស់ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ជាយោបល់បឋមរបស់ខ្លួន។[35]

## ៣.៣. ការចុះផ្សាយអន្តរជាតិ

ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺជាអង្គភាពដែលទទួលខុសត្រូវក្នុងការចុះផ្សាយជាអន្តរជាតិនូវរាល់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញា PCTហើយការចុះផ្សាយជាអន្តរជាតិនេះ ត្រូវធ្វើភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់រយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។[36]

### ៣.៣.១ អានុភាពនៃការចុះផ្សាយអន្តរជាតិ

ការចុះផ្សាយជាអន្តរជាតិនឹងតម្រូវឲ្យមានការការពារនៅតាមបណ្តាប្រទេសសមាជិក PCT ក្នុងករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិនោះទទួលបាននូវការការពារ។ការការពារអាចនឹងមានអនុភាពនៅពេលៈ

- បានផ្តល់ការបកប្រែជាភាសាអង់គ្លេស ដោយការិយាល័យអន្តរជាតិ ករណីសំណុំលិខិតស្នើសុំអន្តរជាតិមិនដាក់ជាភាសាអង់គ្លេស។ ករណីដែលសំណុំលិខិតដាក់មកភាសា ដែលមិនទទួលស្គាល់ អ្នកដាក់ពាក្យសុំត្រូវមកជាភាសាដែលទទួលស្គាល់ផ្លូវការ។

---

[35] ប្រការ ៩៤ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[36] មាត្រា ២១ (២) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិនិង ប្រការ ៤៨ (២)(៤) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

- បានទទួលដោយការិយាល័យចុះបញ្ជីនៃប្រទេសជ្រើសរើសនូវច្បាប់ចតចម្លងនៃការបោះពុម្ពផ្សាយតក្កកម្មដែលចុះបញ្ជីតាមនីតិវិធីសន្ធិសញ្ញា PCT និង
- បានបោះពុម្ពផ្សាយបន្ទាប់ពីការផុតកំណត់នៃរយៈពេល១៨ខែគិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។

រាល់ការចុះផ្សាយសំណុំឯកសារស្នើចុះបញ្ជីតាមសន្ធិសញ្ញា PCT នឹងត្រូវចុះផ្សាយក្នុងប្រព័ន្ធ PATENTSCOPE ដើម្បីឲ្យតតិយជនអាចពិនិត្យ។

### ៣.៣.២ ភាសានៃការចុះផ្សាយអន្តរជាតិ

ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិដាក់ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង ជប៉ុន អាឡឺម៉ង់ កូរ៉េ ព័រទុយហ្គាល់ រុស្ស៊ី ឬ អេស្ប៉ាញ នោះការចុះផ្សាយអន្តរជាតិ ក៏ជាភាសាដូចនឹងសំណុំលិខិតស្នើសុំអន្តរជាតិដែរ ក៏ប៉ុន្តែផ្នែកខ្លះនៃសំណុំលិខិតស្នើសុំអន្តរជាតិនោះដូចជា ចំណងជើងតក្កកម្ម សេចក្តីសង្ខេប និង របាយការណ៍ស្រាវជ្រាវអន្តរជាតិ ត្រូវបកប្រែជាភាសាអង់គ្លេសដោយការិយាល័យអន្តរជាតិ។[37]

## ៣.៤ នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែមនិង របាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម

### ៣.៤.១ នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម

អ្នកដាក់ពាក្យសុំមានជម្រើសមួយបន្ថែមទៀតលើការស្រាវជ្រាវជ្រាវអន្តរជាតិគឺ ការស្រាវជ្រាវជាអន្តរជាតិបន្ថែម ដែលស្រាវជ្រាវដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិមួយផ្សេងទៀត។ គោលបំណងនៃការស្រាវជ្រាវជាអន្តរជាតិបន្ថែមនេះ គឺដើម្បីផ្តល់ការបំពេញបន្ថែមនៃស្រាវជ្រាវស្វែងរក ស្នាដៃដែលមានពីមុនឱ្យកាន់តែទូលំទូលាយ។

អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យស្នើសុំការស្រាវជ្រាវអន្តរជាតិបន្ថែមនៅការិយាល័យអន្តរជាតិក្នុងរយៈពេល ១៩ខែ គិតចាប់ពីកាលបរិច្ឆេទការទាមទារអាទិភាព និងត្រូវបង់កម្រៃតាមការកំណត់ក្នុងរយៈពេល ០១ខែ បន្ទាប់ពីបានដាក់ពាក្យសុំ។ បន្ទាប់មក ការិយាល័យអន្តរជាតិនឹងបញ្ជូនសំណុំឯកសារច្បាប់ចម្លងសម្រាប់ការស្រាវជ្រាវបន្ថែម ទៅអាជ្ញាធរស្រាវជ្រាវអន្តរជាតិមួយផ្សេង ខុសពីអាជ្ញាធរដែលបានស្រាវជ្រាវអន្តរជាតិមុន។ សំណុំឯកសារច្បាប់ចម្លងសម្រាប់ការស្រាវជ្រាវបន្ថែមដែលត្រូវបញ្ជូនមានដូចជា៖

- ពាក្យស្នើសុំការស្រាវជ្រាវបន្ថែម

---

[37] មាត្រា ២១ (៤) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និងប្រការ ៥៥.១ ៤៨.៣ និង ៤៨.៣(ខ) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

- សំណុំលិខិតស្នើសុំអន្តរជាតិ
- ច្បាប់ចម្លងអេឡិចត្រូនិចនៃការចុះលេខបន្តបន្ទាប់
- រាល់ឯកសារបកប្រែដែលបានប្រើសម្រាប់ការស្រាវជ្រាវបន្ថែម
- របាយការណ៍ស្រាវជ្រាវអន្តរជាតិ និង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ
- លិខិតអញ្ជើញចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិឲ្យបង់កម្រៃស្រាវជ្រាវបន្ថែម និង
- រាល់ការជំទាស់នានារបស់អ្នកដាក់ពាក្យសុំលើការស្រាវជ្រាវរបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ

បន្ទាប់ពីទទួលបានឯកសារពាក់ព័ន្ធខាងលើចប់សព្វគ្រប់ពីការិយាល័យអន្តរជាតិ អាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមនឹងចាប់ផ្តើមការងាររបស់ខ្លួន ឲ្យបានមុនកាលបរិច្ឆេទបញ្ចប់ នៃរយៈពេល ២២ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។[38]

ករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិចម្បងបានរកឃើញថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម ហើយអ្នកដាក់ពាក្យសុំមិនបានបង់កម្រៃស្រាវជ្រាវអន្តរជាតិបន្ថែម ដូច្នេះអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមមិនចាំបាច់ស្រាវជ្រាវបន្ថែមទៀតនោះទេ។[39]

ករណីដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមបានរកឃើញថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម នោះអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមនឹងមិនឲ្យអ្នកដាក់ពាក្យសុំបង់កម្រៃនៃការស្រាវជ្រាវបន្ថែមនោះទេ ហើយអាជ្ញាធរនោះនឹងរៀបចំរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម ហើយជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីការយល់ឃើញរបស់ខ្លួនថា សំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលគ្នានៃតក្កកម្ម។ ជាមួយគ្នានេះ អ្នកដាក់ពាក្យសុំនោះអាចស្នើសុំឲ្យអាជ្ញាធរស្រាវជ្រាវអន្តរជាតិបន្ថែមលើនោះ ពិនិត្យបន្ថែមការផ្តល់យោបល់នោះ ដោយមានការបង់កម្រៃបន្ថែម។[40]

### ៣.៤.២ របាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម

អាជ្ញាធរដែលត្រូវបានជ្រើសរើសឱ្យស្រាវជ្រាវអន្តរជាតិបន្ថែម នឹងត្រូវចេញរបាយការណ៍ស្រាវជ្រាវបន្ថែមក្នុងរយៈពេល ២៨ ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ហើយរបាយការណ៍នេះ មានតម្លៃស្មើនឹងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ។

ជាទូទៅរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែមនឹងធ្វើការពន្យល់យ៉ាងជាក់លាក់លើឯកសារ

[38] ប្រការ ៩៨ ចំណុច ៥(ក) នៃវិធានសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[39] ប្រការ ១៣ ចំណុច ៥(ផ) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[40] ប្រការ ៤៥.៦ (ក) (គ) (ឃ) (ង) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

គាំទ្រ (Citations of Documents) លម្អិតជាងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិចម្បង ក្នុងគោលបំណងឲ្យយល់កាន់តែច្បាស់អំពីតក្កកម្មពីមុន (prior art)[41] ហើយមិនមានការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ដូចរបាយការណ៍ស្រាវជ្រាវអន្តរជាតិចម្បងឡើយ។ បន្ទាប់ពីចេញរបាយការណ៍ស្រាវជ្រាវអន្តរជាតិបន្ថែម អាជ្ញាធរមានសម ត្ថកិច្ចនោះនឹងបញ្ជូនរបាយការណ៍របស់ខ្លួនមួយច្បាប់ទៅអ្នកដាក់ពាក្យសុំនិង មួយច្បាប់ទៀតទៅការិយាល័យអន្តរជាតិដើម្បីឲ្យការិយាល័យអន្តរជាតិបញ្ជូនបន្តទៅការិយាល័យជ្រើសរើសរបស់អ្នក ដាក់ពាក្យសុំ។

## ៣.៥. ការពិនិត្យជំហានដំបូងអន្តរជាតិនិងរបាយការណ៍ពិនិត្យ ជំហានដំបូងអន្តរជាតិ

### ៣.៥.១ ការពិនិត្យជំហានដំបូងអន្តរជាតិ

ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនពេញចិត្តនឹងការផ្តល់យោបល់ជាលា យ លក្ខ ណ៍ អក្សរ ដែល ចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ អ្នកដាក់ពាក្យសុំអាចបន្តពិនិត្យលក្ខណវិនិច្ឆ័យនៃតក្កកម្មរបស់ខ្លួនក្រោមនីតិវិធីការពិនិត្យជំហានដំបូងអន្តរជាតិ។ ការពិនិត្យជំហានដំបូងអន្តរជាតិ គឺជានីតិវិធីដែលអ្នកដាក់ពាក្យសុំអាចជ្រើសរើស និង ដាក់ពាក្យទាមទារដាច់ដោយឡែកពីសំណុំលិខិតស្នើសុំអន្តរជាតិទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិហៅកាត់ថា(IPEA)ដោយផ្ទាល់។ ការិយាល័យទទួលត្រូវតែជ្រើសតាំងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអាចជាការិយាល័យជាតិនៃប្រទេសហត្ថលេខីឬ ការិយាល័យថ្នាក់តំបន់ ដែលមានសមត្ថភាពក្នុងការអនុវត្តការពិនិត្យជំហានដំបូងអន្តរជាតិជាមុនសិន។ ករណីដែលការិយាល័យទទួលមានអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិច្រើនជាងមួយ អ្នកដាក់ពាក្យសុំ អាចជ្រើសតាំងអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរទាំងនោះ។ សូមបញ្ជាក់ថា រាល់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅ ឬ ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ គ្រប់ការិយាល័យជាតិនៃប្រទេសហត្ថលេខី គឺអាចជាការិយាល័យជ្រើសតាំងឲ្យជាអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិបាន។[42]

កម្មវត្ថុនៃការពិនិត្យជំហានដំបូងអន្តរជាតិគឺ ចងក្រងយោបល់ជាជំហានដំបូងនិងឲ្យយោបល់លើលក្ខណៈវិនិច្ឆ័យ ថាតើតក្កកម្មដែលស្នើសុំនោះមានភាពថ្មី មានជំហានរកឃើញថ្មី និងអាចយកមកអនុវត្តក្នុងឧស្សាហកម្មដែរឬទេ ដើម្បីពិនិត្យឲ្យដឹងថាតក្កកម្មនោះដែលបានអះអាងអាចទទួលបានប្រកាសនីយបត្រតក្កកម្មបានដែរឬទេ។ អ្នកដាក់ពាក្យសុំអាចពិចារណាជ្រើសរើសនីតិវិធីពិនិត្យជំហានដំបូងជាអន្តរជាតិនេះ ព្រោះនីតិវិធីនេះនឹងនាំឲ្យអ្នកដាក់ពាក្យសុំដឹងជាមុន ដើម្បីធ្វើការកែ

---

[41] ប្រការ ៩៥.៧ (យ) (ង) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[42] មាត្រា ៣១(៤), ៦៤(១) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៥៣.៧ និង ៩០.៨ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

សម្រួលសេចក្តីអត្ថាធិប្បាយ ការអះអាងនិងគំនូរបង្ហាញនៃសំណុំឯកសារស្នើសុំរបស់ខ្លួនជៀសវាងការជំទាស់ក្នុងការចុះបញ្ជីនៅការិយាល័យជាតិឬ នាំឲ្យខាតពេលវេលាពេលនៅក្នុងដំណាក់កាលថ្នាក់ជាតិ។[43]

**ក.ការទាមទារ**

ការទាមទារ គឺជាពាក្យបច្ចេកទេសនៅក្នុងសន្ធិសញ្ញា PCT ដើម្បីសំដៅការស្នើសុំការពិនិត្យជំហានដំបូងអន្តរជាតិ។ ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិត្រូវដាក់ទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិដែលមានសមត្ថកិច្ចក្នុងរយៈពេល ០៣ខែ គិតចាប់ថ្ងៃបញ្ជូនរបាយការស្រាវជ្រាវអន្តរជាតិ និង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ឬ ក្នុងរយៈពេល ២២ខែ គិតចាប់ពីកាលបរិច្ឆេទទាមអារអាទិភាព។[44]

ពោលគឺការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិមិនទាន់អាចចាប់ផ្តើមបានឡើយ រហូតដល់អាជ្ញាធរស្រាវជ្រាវអន្តរជាតិបានចាប់ផ្តើមនីតិវិធីសរសេររបាយការណ៍ស្រាវជ្រាវអន្តរជាតិ និង ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់ខ្លួន។ អ្នកដាក់ពាក្យសុំត្រូវរងចាំឯកសារទាំងពីរខាងលើសិន មុននឹងសម្រេចដាក់ពាក្យ ទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបាន។

ដើម្បីអាចដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបានលុះតែគោរព តាមលក្ខខណ្ឌចំនួន ០២ ដូចខាងក្រោមៈ

- លក្ខខណ្ឌទី១ អ្នកដាក់ពាក្យសុំត្រូវមានអាសយដ្ឋាន ឬ សញ្ជាតិនៃប្រទេសសមាជិកដែលព្រមទទួលការអនុវត្តក្នុងជំពូកទី២ នៃសន្ធិសញ្ញា PCT និង
- លក្ខខណ្ឌទី២សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែដាក់នៅការិយាល័យទទួលនៃប្រទេសមាជិកដែលព្រមទទួលការអនុវត្តក្នុងជំពូកទី២ នៃសន្ធិសញ្ញា PCT[45]។

**ខ.ការកែសម្រួលសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូរបង្ហាញ**

មុននឹងចេញរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ អ្នកដាក់ពាក្យសុំ មានឱកាស ក្នុងការកែសម្រួលសំណុំលិខិតស្នើសុំជាអន្តរជាតិបាន នៅក្នុងលក្ខខណ្ឌតម្រូវ និងមានពេលវេលាកំណត់ (សំដៅដល់ការកែសម្រួលសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូរបង្ហាញបាន) តែការកែសម្រួលនោះមិនត្រូវប្រាសចាកពីការបង្ហាញឲ្យដឹង នៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ

[43] មាត្រា ៣១, ៣២, ៣៣ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[44] មាត្រា ៣៩(១) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិនិង ប្រការ ៥៤ ១(ក)(៣) និង ៦៩.២ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[45] មាត្រា ៣១ (២)(ក) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិនិងប្រការ ១៨.១ និង ៥៤ នៃ វិធាក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ដែលបានដាក់នោះឡើយ។[46]

**គ-ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ**

អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ នឹងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅដល់អ្នកដាក់ពាក្យសុំដោយបញ្ជាក់អំពីហេតុផលច្បាស់លាស់។ ការទាមទារពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅថ្ងៃ ឬ ក្រោយថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិនឹងប្រើយន្តការស្វែងរកដែលមានឈ្មោះថា top up។ យន្តការស្វែងរកនេះមានសមត្ថភាពអាចបញ្ជាក់ អំពីឯកសារពាក់ព័ន្ធបន្ថែមអំពីឯកសារតក្កកម្មពីមុនឲ្យអ្នកដាក់ពាក្យសុំដឹង និង មានឱកាសកែសម្រួលពាក្យសុំរបស់ខ្លួន ដើម្បីធានាកុំឲ្យមានការបដិសេធថា តក្កកម្មកំពុងស្នើសុំនេះមិនមានភាពថ្មី ឬមិនមានជំហាននៃការរកឃើញថ្មី មុនចាប់ផ្តើមនីតិវិធីកម្រិតថ្នាក់ជាតិ។[47]

ការចេញការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរអាចចេញជាលើកទី២ ដែលផ្តល់ឱកាសឲ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលសំណុំលិខិតស្នើសុំរបស់ខ្លួនបានម្តងទៀត។ ចំនួននៃការផ្តល់ឱកាសឲ្យកែសម្រួលសំណុំលិខិតស្នើសុំ គឺអាស្រ័យលើទៅពេលវេលានៃការពិនិត្យជំហានដំបូង។ របាយការណ៍ស្តីពីការពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវផ្តល់ឲ្យអ្នកដាក់ពាក្យសុំក្នុងអំឡុងពេល ២៨ ខែគិតចាប់កាលបរិច្ឆេទទាមទារអាទិភាព។រាល់ការកែសម្រួលណាដែលធ្វើក្រោយការប្រគល់របាយការណ៍ នឹងមិនត្រូវយកមកពិចារណានោះទេ។[48]

**ឃ.ការឆ្លើយតបនឹងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ជាទូទៅ**

អ្នកដាក់ពាក្យសុំនឹងទទួលការផ្តល់យោបល់ និង ការអនុញ្ញាតឲ្យឆ្លើយតបទៅអាជ្ញាធរពិនិត្យជំហានដំបូង នៅមុនពេលប្រគល់របាយការណ៍ស្តីអំពីការពិនិត្យជំហានដំបូងអន្តរជាតិ។ នៅក្នុងករណីនេះ អ្នកដាក់ពាក្យសុំអាច ឲ្យកែសម្រួល និង ផ្តល់អំណះអំណាងរបស់ខ្លួនបាន។

អ្នកដាក់ពាក្យសុំមានសិទ្ធិទាក់ទងផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរជាមួយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិបាន ដែលជាទំនាក់ទំនងក្រៅផ្លូវការ និង មិនចងកាតព្វកិច្ចលើកលែងតែការតវ៉ា ដែលពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្ម។[49]

**៣.៥.២ របាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ**

នីតិវិធីការពិនិត្យជំហានដំបូងអន្តរជាតិ នឹងបញ្ចប់នៅពេលរបាយការណ៍ការពិនិត្យជំហាន

---

[46] មាត្រា៣៤ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[47] ប្រការ ៦៦ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[48] ប្រការ ៦៦ និង ប្រការ ៦៦.៤(ក) នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[49] ប្រការ ៦៦ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ដំបូងអន្តរជាតិបានរៀបចំរួចរាល់ ដែលត្រូវធ្វើក្នុងរយៈពេល ២៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ឬ រយៈពេល ០៦ខែ គិតចាប់ពីកាលបរិច្ឆេទទទួលការទាមទារដោយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ។ របាយការណ៍ស្តីពីការពិនិត្យជំហានដំបូងអន្តរជាតិមិនចងកាតព្វកិច្ចនោះទេ តែរបាយការណ៍នេះនឹងផ្តល់យោបល់ដោយពិចារណាលើលក្ខណវិនិច្ឆ័យដែលត្រូវបំពេញថាតើតក្កកម្មនោះមានភាពថ្មី មានជំហាននៃការបង្កើតថ្មី និងអាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មបាន ឬទេ។ [50] ជាទូទៅរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវរៀបចំចប់សព្វគ្រប់ និងបញ្ជូនមកអ្នកដាក់ពាក្យសុំ ០២ខែ មុនចាប់ផ្តើមអនុវត្តនីតិវិធីថ្នាក់ជាតិ ដូច្នេះក្នុងរយៈពេលនេះអ្នកដាក់ពាក្យសុំ អាចនឹងពិចារណាថាគួរបន្តនីតិវិធីថ្នាក់ជាតិឬយ៉ាងណា។[51]

បន្ទាប់ពីរៀបចំរួច អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិត្រូវបញ្ជូនរបាយការណ៍នេះទៅអ្នកដាក់ពាក្យសុំ និង ទៅការិយាល័យអន្តរជាតិ ដែលរបាយការណ៍ត្រូវសរសេរដូចនឹងភាសានៃសំណុំលិខិតស្នើសុំអន្តរជាតិ និង ភាសាដែលនឹងត្រូវបោះផ្សាយជាអន្តរជាតិ។ ការិយាល័យអន្តរជាតិត្រូវតែបកប្រែភាសានោះទៅជាភាសាអង់គ្លេស ក្នុងករណីភាសាប្រើប្រាស់ មិនមែនជាភាសាអង់គ្លេស។[52]

របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិនឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ដឹង ក្រៅពីអ្នកដាក់ពាក្យសុំ និង មន្ត្រីដែលបានជ្រើតាំងក្នុងដំណាក់ការថ្នាក់អន្តរជាតិឡើយ។ ការិយាល័យអន្តរជាតិ និង អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ មិនត្រូវផ្តល់ព័ត៌មានស្តីអំពីការចេញរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ឬ ការដកការទាមទារ ឬ ការមិនដកការទាមទារទៅអ្នកផ្សេងដោយគ្មានការអនុញ្ញាត ឬ ការស្នើសុំពីអ្នកដាក់ពាក្យសុំ។[53]

នៅពេលទទួលបានរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ ហើយអ្នកដាក់ពាក្យសុំសម្រេចថាតើបន្តនីតិវិធីថ្នាក់ជាតិ ឬ កម្រិតតំបន់នៅចំពោះមុខមន្ត្រីដែលបានជ្រើសតាំងក្នុងរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ របាយការណ៍នេះនឹងជាមូលដ្ឋានដ៏សំខាន់សម្រាប់ការិយាល័យជ្រើសតាំងក្នុងពិចារណាក្នុងផ្តល់ប្រកាសនីយបត្រតក្កកម្មថ្នាក់ជាតិដល់សំណុំលិខិតស្នើសុំអន្តរជាតិណាដែលក្រោយពីបានពិនិត្យឃើញថាបំពេញតាមលក្ខណៈវិនិច្ឆ័យសំខាន់ៗ

[50] មាត្រា ៣៥(១) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៦៩.២ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[51] ប្រការ ៦៩.២ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[52] ប្រការ ៧០, ៧២, ៧៤ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

[53] មាត្រា ៣៦(៤) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ទាំង ៣ នៃតក្កកម្មត្រូវបានបំពេញ។[54]

## ៣.៦. ការពិនិត្យថ្នាក់ជាតិ

បន្ទាប់ពីបញ្ចប់ដំណាក់កាលនីតិវិធីថ្នាក់អន្តរជាតិ នីតិវិធីនេះនឹងត្រូវបន្តពិនិត្យនៅកម្រិតជាតិដែលជាដំណាក់កាលបញ្ចប់នៃនីតិវិធីចុះបញ្ជីប្រកាសសនីយបត្រតក្កកម្មតាម PCT។ ទោះបីយ៉ាងណា ការពិនិត្យថ្នាក់ជាតិនឹងចាប់ផ្តើមហើយអ្នកដាក់ពាក្យសុំត្រូវអនុវត្តសកម្មភាពមួយចំនួនដែលបានកំណត់ឲ្យបានមុនការផុតកំណត់នៃកាលបរិច្ឆេទ។ គួរបញ្ជាក់ផងដែរថា អ្នកដាក់ពាក្យសុំត្រូវមានទំនួលខុសត្រូវខ្លួនឯងក្នុងការចាប់ផ្តើមការពិនិត្យថ្នាក់ជាតិឲ្យបានទាន់ពេលកំណត់របស់ច្បាប់។ រយៈពេលដើម្បីទទួលការពិនិត្យកម្រិតជាតិត្រូវចាប់ផ្តើមពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិមិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទ អាទិភាព។[55]

### ៣.៦.១. សំណុំឯកសារចាំបាច់

មុនការចាប់ផ្តើមនីតិវិធីត្រួតពិនិត្យបន្តនៅថ្នាក់ជាតិ អ្នកដាក់ពាក្យសុំត្រូវផ្តល់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ព្រមជាមួយរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិ និង បង់កម្រៃថ្នាក់ជាតិ ជូនដល់ការិយាល័យជ្រើសរើសនីមួយៗដោយមិនឲ្យយឺតជាងការផុតកំណត់នៃរយៈពេល៣០ខែគិតចាប់ពីកាលបរិច្ឆេទអាទិភាព។[56] ទន្ទឹមនឹងនេះការិយាល័យជ្រើសរើសនឹងតម្រូវឲ្យមានអ្នកតំណាងដែលមានសញ្ជាតិមិនដូចនឹងអ្នកដាក់ពាក្យសុំនិងមានការិយាល័យបម្រើការងារនៅប្រទេសជ្រើសរើស។[57]

### ៣.៦.២. ការត្រួតពិនិត្យ

ក្នុងដំណាក់កាលនីតិវិធីអន្តរជាតិ ជាទូទៅសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបានស្រាវស្រាវ និង ត្រួតពិនិត្យដោយអាជ្ញាធរស្រាវជ្រាវ ឬ/និង អាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលពាក្យសុំរបស់ខ្លួនបាន។ របាយការណ៍ទាំងនោះនឹងបង្កភាពងាយស្រួលដល់អ្នកដាក់ពាក្យសុំបានដឹងជាមុនអំពីភាពដែលទទួលបានប្រកាសនីយបត្រតក្កកម្មជាតិ។

ទោះបីជាយ៉ាងណា របាយការណ៍ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬអាជ្ញាធរ

54 មាត្រា ៣៦ (៤) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ និង ប្រការ ៧១.២ នៃវិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

55 មាត្រា ២២ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

56 មាត្រា ២២នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

57 មាត្រា ២៧(៧) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ត្រួតពិនិត្យជំហានដំបូងអន្តរជាតិមិនចងកាតព្វកិច្ចដល់ការិយាល័យចុះបញ្ជីជាតិនោះទេ ពោលរបាយការណ៍ទាំងនោះគ្រាន់ផ្តល់យោបល់ ថាតើសំណុំលិខិតស្នើសុំអន្តរជាតិនោះ បានបំពេញតាមលក្ខខណ្ឌ៖ ភាពថ្មី មានជំហាននៃការរកឃើញថ្មី និង អាចអនុវត្តក្នុងវិស័យឧស្សាហកម្មបានដែរឬទេ។

**៣.៦.៣ ការកែសម្រួលនៅដំណាក់កាលនីតិវិធីកម្រិតជាតិ**

នៅក្នុងដំណាក់កាលនីតិវិធីថ្នាក់ជាតិ អ្នកដាក់ពាក្យសុំអាចធ្វើកែសម្រួលបន្ថែមនៅចំពោះមុខការិយាល័យចុះបញ្ជីជាតិបាន លើសេចក្តីអះអាង សេចក្តីអធិប្បាយនិង គំនូសបង្ហាញ ហើយការកែសម្រួលនេះ គឺជាការបំពេញបន្ថែមទៅលើការអនុវត្តដំណាក់ការនីតិវិធីថ្នាក់អន្តរជាតិកន្លងមក និងឲ្យសមស្របទៅតាមច្បាប់ជាតិរដ្ឋជ្រើសរើសនីមួយៗ។ ទោះបីជាយ៉ាងណាការកែសម្រួលនៅដំណាក់កាលនេះមិនត្រូវឲ្យខុសឆ្ងាយពីការបញ្ចេញឲ្យដឹងអំពីតក្កកម្មនៃសំណុំលិខិតស្នើសុំអន្តរជាតិដើមឡើយ។[58]

[58] មាត្រា ២៨ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

## ជំពូកទី៤. លក្ខណៈពិសេសមួយចំនួននៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម

គេសង្កេតឃើញថា ការផ្តល់ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជាអាចធ្វើបានតាមរយៈការធ្វើសហប្រតិបត្តិការជាអន្តរជាតិ ដែលក្នុងនោះរួមមានប្រកាសស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលក្នុងការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅ នឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កម្មជប៉ុន ប្រកាសស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ប្រកាសស្តីពីការកំណត់គោលការណ៍ និង នីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជាប្រកាសស្តីពី ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋ ប្រជាមានិតចិននៅកម្ពុជា។

### ៤.១.ការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន

ប្រកាសលេខស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅ នឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ កំណត់ពីនីតិវិធីសម្រាប់ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ដែលទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ដោយអនុលោមតាមមាត្រា ១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មកម្ពុជា។[59]

#### ៤.១.១ សមត្ថកិច្ចទទួលបន្ទុក

ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោម កិច្ចសហប្រតិបត្តិការសម្របសម្រួលផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាដែលទាក់ទងទៅនឹង ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយ

[59] ប្រការ ១ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុនត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃ អគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។[60]

### ៤.១.២. ការដាក់ពាក្យស្នើសុំ

#### ក. អ្នកដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យសុំអាចស្នើសុំពន្លឿនការផ្តល់ ប្រកាសនីយបត្រតក្កកម្មបានចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលដាក់នៅក្រសួងឧស្សាហកម្មនិងសិប្បកម្មដោយប្រើប្រាស់លទ្ធផលស្រាវជ្រាវនិងពិនិត្យតក្កកម្មដែល ត្រូវបានធ្វើឡើងដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន។[61]

#### ខ. ទម្រង់ពាក្យស្នើសុំ

អ្នកដាក់ពាក្យសុំត្រូវប្រើទម្រង់ពាក្យសុំនិងត្រូវបំពេញទិន្នន័យដូចខាងក្រោម៖

- ចំណងជើងតក្កកម្ម
- កាលបរិច្ឆេទដាក់ពាក្យស្នើសុំ
- លេខសំណុំលិខិតស្នើសុំ
- ឈ្មោះអ្នកដាក់ពាក្យសុំ
- សំណុំលិខិតស្នើសុំទាក់ទងទៅនឹងអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុននិង
- ឯកសារភ្ជាប់មួយចំនួនទៀតដែលត្រូវផ្តល់ដូចខាងក្រោម៖
  - ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុនដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន។
  - តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង
  - បកប្រែជាភាសាអង់គ្លេសនូវសេចក្តីអះអាងនិងលក្ខណៈបច្ចេកទេសដែលពិពណ៌នានៅក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម។
  - បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេសដែល ពិពណ៌នានៅក្នុងព្រឹត្តបត្រប្រកាស នីយបត្រតក្កកម្ម។

---

[60] ប្រការ ២ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

[61] ប្រការ ៣ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

- អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេល ៦ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម។[62]

**គ.លក្ខខណ្ឌដែលការស្នើសុំត្រូវបានទទួលយក**

ការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានទទួលយកចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្មដែលបានដាក់នៅក្រសួងឧស្សាហកមម្មនិង សិប្បកម្មស្របតាមលក្ខខណ្ឌដូចខាងក្រោមៈ

១. ពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវមានការប្រកាសសិទ្ធិអាទិភាពក្រោម អនុសញ្ញាក្រុងប៉ារីសស្តីពី ការការពារកម្មសិទ្ធិឧស្សាហកម្ម ផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ឬ

២. ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបម្រើជាមូលដ្ឋានសម្រាប់ប្រកាសសិទ្ធិអាទិភាពក្រោមអនុសញ្ញាក្រុងប៉ារីសស្តីពី ការការពារកម្មសិទ្ធិឧស្សាហកម្មដោយ ផ្អែកលើមូលដ្ឋាន នៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុនរួមទាំង ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោម សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលជាតិ ឬ

៣. ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលមានមូលដ្ឋានដូចគ្នាទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសម្រាប់ប្រកាសសិទ្ធិអាទិភាពក្រោមអនុសញ្ញាក្រុងប៉ារីសស្តីពី ការការពារកម្មសិទ្ធិឧស្សាហកម្មដោយផ្អែកលើមូលដ្ឋាននៃពាក្យសុំរបស់អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុនរួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលជាតិ។[63]

**ឃ.ការបង់កម្រៃ**

ការពន្លឿនក្នុងការផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយ

[62] ប្រការ ៥ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

[63] ប្រការ ៤ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

អង្គភាពប្រកាសនីយបត្រតក្កម្មជប៉ុន ពុំមានការបង់កម្រៃសេវាឡើយ។[64]

## ៤.២. ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា

ប្រកាសស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦បានកំណត់ពីនីតិវិធីនៃការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា និងបំពេញបន្ថែមលើប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម**កម្ពុជា** ដោយអនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម។[65]

### ៤.២.១ សមត្ថកិច្ចចុះបញ្ជី

ការស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាត្រូវធ្វើនៅ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។[66]

### ៤.២.២ ការដាក់ពាក្យស្នើសុំចុះបញ្ជី

#### ក. ទម្រង់ពាក្យសុំចុះបញ្ជី

ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ត្រូវបំពេញតាមគំរូលិខិតយថាភូតឲ្យបានត្រឹមត្រូវនូវៈ

- ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋាន របស់អ្នកដាក់ពាក្យសុំនីមួយៗនិងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំនីមួយៗផងដែរ។
- ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំចុះបញ្ជីត្រូវបញ្ជាក់ និងបង្ហាញពីឈ្មោះនិង អាសយដ្ឋានរបស់ភ្នាក់ងារនោះនិង ត្រូវមានលិខិតផ្ទេរសិទ្ធិតំណាងភ្ជាប់មកជាមួយ។
- ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ
    - ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដោយមានការបញ្ជាក់

[64] ប្រការ ៧ នៃប្រកាសលេខ ១៨១ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

[65] ប្រការ ១ នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

[66] ប្រការ ៣ នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

ថាបានចម្លង ត្រឹមត្រូវតាមច្បាប់ដើមពីអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី។

- ឯកសារចម្លងសេចក្ដីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដោយមានការបញ្ជាក់ពីអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ដែលបានផ្ដល់រួមមានៈ
  - សេចក្ដីអធិប្បាយ
  - សេចក្ដីអះអាង
  - គំនូរបង្ហាញ(ប្រសិនបើមាន) លំដាប់បញ្ជី(ប្រសិនបើមាន)។

- ថតចម្លងខ្លឹមសារសង្ខេបនៃប្រកាសនីយបត្រតក្កកម្មសិង្ហបុរីដែលបានផ្ដល់
- ឯកសារបកប្រែជាភាសាខ្មែរត្រូវផ្ដល់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦ខែ គិតចាប់ពីកាលបរិច្ឆេទ ដែលបានដាក់សំណើសុំចុះបញ្ជីទៅមន្ត្រីកាន់កាប់បញ្ជី។
- ការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបង់ក្នុងកម្រៃសេវា ស្របតាមប្រកាសរួមលេខ ៧១៧ សហវ-ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[67]

**ខ.លក្ខខណ្ឌតម្រូវសម្រាប់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់**

ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ត្រូវស្របនឹងប្រការ ៦ ហើយត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោមៈ

- ត្រូវមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា
- ត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីក្រោយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ និងត្រូវស្របតាមមាត្រា ៤ និង មាត្រា៩ នៃច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។[68]

**គ. ភារកិច្ចមន្ត្រីកាន់កាប់បញ្ជី**

[67] ប្រការ ៤ នៃប្រកាសលេខ ១៨២ ស្ដីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

[68] ប្រការ ៥ នៃប្រកាសលេខ ១៨២ ស្ដីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សម្គាល់នៅលើឯកសារនីមួយៗ នៃសំណុំលិខិតស្នើសុំនូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលពាក្យសុំ និងលេខសំណុំលិខិតស្នើសុំដែលផ្គុំដោយអក្សរ "កជ" បន្ទាត់ទ្រេត / អក្សរ "ចទប្រត"បន្ទាត់ ទ្រេត "/ លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល។[69]

**ឃ. ការត្រួតពិនិត្យលើពាក្យស្នើសុំ**

ការត្រួតពិនិត្យលើពាក្យស្នើសុំត្រូវអនុវត្តដូចខាងក្រោម៖

- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យលើពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម ដែលត្រូវបំពេញឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃប្រការ ៤ និងប្រការ៥ នៃប្រកាសនេះ។
- ប្រសិនបើមានតម្រូវការចាំបាច់ណាមួយមន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំឲ្យមកផ្តល់ឯកសារកែតម្រូវទាំងអស់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃជូនដំណឹង។
- ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវហើយនោះមន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនិងត្រូវចេញវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចុះបញ្ជីនោះជូនអ្នកដាក់ពាក្យស្នើសុំ។
- លេខចុះបញ្ជីប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ត្រូវចុះកំណត់សម្គាល់ ដែលផ្គុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ចទប្រត" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃការចុះបញ្ជី។[70]

**ង. កាលបរិច្ឆេទទទួលពាក្យសុំ**

កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជី ទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា និងកាលបរិច្ឆេទសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ត្រូវអនុវត្តដូចខាងក្រោម៖

- កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា

[69] ប្រការ ៦នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

[70] ប្រការ ៧ នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

គឺជាកាលបរិច្ឆេទ ដែលបានទទួលឯកសារទាំងអស់ និងបង់កម្រៃសេវា។

- កាលបរិច្ឆេទសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា គឺជាកាលបរិច្ឆេទដូចគ្នា នឹងកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម នៅសិង្ហបុរី។
- កាលបរិច្ឆេទចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា គឺជាកាលបរិច្ឆេទ ចេញវិញ្ញាបនបត្រចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅម្ពុជា។ [71]

**ច.ការអនុវត្តនៃប្រកាសនីយបត្រតក្កកម្មសិង្ហបុរីដែលត្រូវចុះបញ្ជីទទួលស្គាល់នៅកម្ពុជា**

ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដែលត្រូវចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដែលត្រូវចុះបញ្ជីទទួលស្គាល់នៅកម្ពុជា អនុវត្តដូចប្រកាសនីយបត្រតក្កកម្ម ដែលត្រូវផ្តល់ដោយមន្ត្រីកាន់កាប់បញ្ជី ហើយស្របតាមមាត្រា៣៨ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។
- កាលបរិច្ឆេទនៃការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី នៅកម្ពុជាដូចគ្នានឹងកាលបរិច្ឆេទនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ហើយត្រូវស្របតាម មាត្រា៣៨ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។[72]

**ឆ.ការបង់កម្រៃ**

ការបង់ប្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ សម្រាប់ប្រកាសនីយបត្រតក្កកម្មសឹង្ហបុរីនៅកម្ពុជា ត្រូវអនុវត្តដូចខាងក្រោម៖

- ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ត្រូវបង់កម្រៃសេវនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[73]
- កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ដែលបានចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវបង់ដោយរាប់បន្តពីកាលបរិច្ឆេទចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មនោះ ដោយផ្អែកលើកាលបរិច្ឆេទសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម។

---

[71] ប្រការ ៨ នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

[72] ប្រការ ៩ នៃប្រកាសលេខ ១៨២ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

[73] ដូចមានចែងក្នុងប្រកាសរួមលេខ ៧១៧ សហវ-ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ សម្រាប់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ត្រូវបង់ក្នុងរយៈពេល ៣ខែ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងបង់ប្រាក់។[74]

## ៤.៣.ការកំណត់គោលការណ៍និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា

ប្រកាសស្តីពីការកំណត់គោលការណ៍និង នីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជាចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧មានគោលបំណងអនុវត្តការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជាអនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាព នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រ តក្កកម្មអឺរ៉ុប។[75] ប្រកាសនេះមានគោលដៅៈ

- កំណត់អំពីនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា
- កំណត់បែបបទនៃការរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា
- កំណត់យន្តការទទួលបន្ទុកពិនិត្យ និងគ្រប់គ្រងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាពនៅកម្ពុជា។[76]

ប្រកាសនេះ អនុវត្តចំពោះសំណុំលិខិតស្នើសុំទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបអនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។[77]

### ៤.៣.១ សមត្ថកិច្ចទទួលបន្ទុក

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីត្រូវទទួលពិនិត្យសំណុំលិខិតស្នើសុំទទួលស្គាល់សុពលភាព

[74] ប្រការ ១០ នៃប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

[75] ប្រការ ១ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

[76] ប្រការ ២ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

[77] ប្រការ ៣ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ដើម្បីធ្វើការគ្រប់គ្រង និងការពារកម្មសិទ្ធិបញ្ញារបស់តក្កករ ដែលបានបង្កើតតក្កកម្ម និងការច្នៃប្រឌិត អនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។[78]

### ៤.៣.២ ការស្នើសុំទទួលស្គាល់សុពលភាព

ការស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មមានដូចខាងក្រោម៖

- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនិងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានផ្តល់ឲ្យតាមសំណុំលិខិតស្នើសុំ ត្រូវបានទទួលស្គាល់សុពលភាព នៅក្នុងប្រទេសកម្ពុជា តាមសំណើរបស់អ្នកដាក់ពាក្យសុំ។ សំណើសុំទទួលស្គាល់សុពលភាពត្រូវបានទទួលយកចំពោះសំណុំលិខិតប្រកាសនីយបត្រតក្កកម្មអឺរ៉ុបណាមួយ ដែលបានដាក់នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងទទួលស្គាល់សុពលភាពរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបោះពុម្ពផ្សាយពាក្យសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មឲ្យបានឆាប់រហ័សបន្ទាប់ពីទទួលបានការជូនដំណឹងពីការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបញ្ជាក់ថាកម្រៃនៃការស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មត្រូវបានបង់រួចប៉ុន្តែមិនមែនធ្វើឡើងនៅមុនពេលផុតកំណត់នៃរយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាព ប្រសិនបើមានការអះអាងពីកាលបរិច្ឆេទអាទិភាព។
- សំណើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានដកនៅពេលណាមួយក៏បាន។ សំណើសុំទទួលស្គាល់សុពលភាពនេះត្រូវបានចាត់ទុកថាបានដកចេញ នៅពេលដែលកម្រៃកំណត់លើការស្នើសុំទទួលស្គាល់សុពលភាព មិនត្រូវបានបង់ទាន់ពេលវេលាឬ នៅពេលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបត្រូវបានបដិសេធដកចេញ ឬចាត់ទុកថាដកចេញនៅទីបញ្ចប់។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបោះពុម្ព

[78] ប្រកាស ៤ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

ផ្សាយឲ្យបានឆាប់ប្រសិនបើការស្នើសុំសុពលភាពត្រូវបានចុះផ្សាយរួចហើយ។[79]

**ក. សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប**

អត្ថបទត្រឹមត្រូវនៃសំណុំលិខិតទាំងនេះ មានដូចខាងក្រោមៈ

- អត្ថបទនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលជាភាសា នៃដំណើរការនីតិវិធីនៅចំពោះមុខការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវតែជាអត្ថបទត្រឹមត្រូវនៅក្នុងដំណើរការនីតិវិធី ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។
- ទោះបីជាប្រកាសនីយបត្រតក្កកម្មដែលបានបកប្រែជាភាសា ដែលកំណត់សម្រាប់ការផ្តល់ការការពារប្រកាសនីយបត្រតក្កកម្មនោះមានវិសាលភាពការពារចង្អៀតជាងអត្ថបទនៃភាសាដើមក៏ដោយនោះ ត្រូវបានចាត់ទុកថាជាអត្ថបទត្រឹមត្រូវលើកលែងតែក្នុងដំណើរការ មោឃភាព។
- ម្ចាស់ប្រកាសនីយបត្រតក្កកម្មនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែល ត្រូវបានទទួលស្គាល់សុពលភាពអាចដាក់ជូននូវការកែតម្រូវនៃការបកប្រែនៅពេលណាក៏បាន។ការបកប្រែដែលបានកែតម្រូវនៃសេចក្តីអះអាងរបស់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពនោះមិនត្រូវមានប្រសិទ្ធភាពផ្នែកច្បាប់ឡើយ រហូតទាល់តែត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
- បុគ្គលដែលប្រើប្រាស់តក្កកម្ម ឬធ្វើឲ្យមានប្រសិទ្ធភាព និងរៀបចំជាក់លាក់ក្នុងការប្រើប្រាស់តក្កកម្មនោះ ក្នុងគោលបំណងល្អនឹងមិនត្រូវចាត់ទុកថាជាការរំលោភបំពានប្រកាសនីយបត្រតក្កកម្ម ក្នុងអត្ថន័យនៃការបកប្រែដើមដំបូង និងក្នុងអត្ថន័យបន្ទាប់ពីការកែតម្រូវនៃការបកប្រែដែលមានប្រសិទ្ធភាពហើយ អាចបន្តការប្រើប្រាស់តក្កកម្ម នោះនៅក្នុងអាជីវកម្មរបស់គាត់ ឬ សម្រាប់សេចក្តីត្រូវការរបស់គាត់ដោយគ្មានការបង់កម្រៃអ្វីឡើយ។[80]

**ខ. ប្រសិទ្ធិភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប**

ប្រសិទ្ធភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបមានដូចខាងក្រោមៈ

- ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពចាប់ពីកាលបរិច្ឆេទបោះពុម្ពផ្សាយអំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវមានសិទ្ធិដូចគ្នានិងដូចអ្វីដែលទទួលបានដោយប្រកាសនីយបត្រតក្កកម្ម ជាតិ។

[79] ប្រការ ៧ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

[80] ប្រការ ១០ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

- ក្នុងរយៈពេល ៣ខែបន្ទាប់ពីកាលបរិច្ឆេទដែលបញ្ជាក់អំពី ការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលបានបោះពុម្ពផ្សាយម្ចាស់នៃ ប្រកាសនីយបត្រតក្កកម្មត្រូវផ្តល់ឲ្យទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម នូវសេចក្តីបកប្រែជាភាសាខ្មែរ និងជាភាសាអង់គ្លេស ហើយត្រូវបង់កម្រៃសម្រាប់ការបោះពុម្ពផ្សាយ តាមការកំណត់។
- ប្រសិនបើប្រកាសនីយបត្រតក្កកម្មអឺរ៉ុបត្រូវបានរក្សា នៅក្នុងទម្រង់កែសម្រួលតាមលទ្ធផលនៃការជំទាស់ឬការស្នើសុំកម្រិតទំហំនៃសេចក្តីអះអាងដែល បានដាក់ពាក្យសុំជាមួយការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុបម្ចាស់នៃ ប្រកាសនីយបត្រតក្កកម្មត្រូវផ្តល់អត្ថបទបកប្រែសេចក្តីអះអាង ដែលបានបកប្រែជាភាសាខ្មែរនិងភាសាអង់គ្លេសដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងត្រូវបង់ថ្លៃសេវាសម្រាប់ការបោះពុម្ពផ្សាយ នៅក្នុងរយៈពេល ៣ខែនៃកាលបរិច្ឆេទដែលការសម្រេចរក្សាសុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ក្នុងទម្រង់កែសម្រួល ឬក្នុងទម្រង់ការកម្រិត ដែលត្រូវបានបោះពុម្ពផ្សាយ។
- ក្នុងករណីអត្ថបទនៃសេចក្តីអះអាងមានការយោងទៅសញ្ញា ដែលបានប្រើប្រាស់ក្នុងគំនូសបង្ហាញ គំនូសបង្ហាញនោះត្រូវដាក់ភ្ជាប់មកជាមួយការបកប្រែ។
- ក្រសួងឧស្សាហកម្មនិងសិប្បកម្មត្រូវបោះពុម្ពផ្សាយឲ្យបានឆាប់រហ័សនូវ សេចក្តីបកប្រែណាមួយ ដែលត្រឹមត្រូវ ហើយដែលបានដាក់ជូនមកនោះ។
- ប្រសិនបើការបកប្រែមិនត្រូវបានផ្តល់ជូនក្នុងពេលវេលាកំណត់ ឬ កម្រៃបោះពុម្ពផ្សាយមិនត្រូវបានបង់នៅក្នុងពេលវេលាកំណត់ទេនោះ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានទទួលស្គាល់សុពលភាពនឹងត្រូវបានចាត់ទុកថា បានបោះបង់ចោលតាំងពីដើមរៀងមក។ សេចក្តីបកប្រែនេះអាចអនុញ្ញាតឲ្យផ្តល់ឲ្យក្នុងអំឡុងពេល (៣)ខែ បន្ថែមទៀតចាប់ពីពេលដែលបានផុតកំណត់។
- ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព ត្រូវបានចាត់ទុកថាមិនមានប្រសិទ្ធភាពចំពោះករណីដែលប្រកាសនីយបត្រតក្កកម្ម ដែលត្រូវបានលុបចោលនៅក្នុងដំណើរការនីតិវិធីជំទាស់ ឬនៅក្នុងកិច្ចដំណើរការនីតិវិធីវិនិច្ឆ័យ ឬការកម្រិតនៅក្នុងនីតិវិធីកម្រិតទំហំនៃសេចក្តីអះអាង ដែលធ្វើឡើងដោយការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។[81]

[81] ប្រការ ៩ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

**គ. សិទ្ធិនៃកាលបរិច្ឆេទមុន**

សិទ្ធិនៃកាលបរិច្ឆេទមុនមានដូចជា៖

- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានបង់កម្រៃទទួលស្គាល់សុពលភាព និងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពរួចហើយត្រូវចាត់ទុកថាជាស្នាដៃតក្កកម្មមុនមានប្រសិទ្ធភាពដូចគ្នា នឹងសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មជាតិ។
- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មជាតិត្រូវចាត់ទុកថាមានប្រសិទ្ធភាពដូចគ្នានឹង ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព។[82]

**ឃ. ការការពារកើតឡើងក្នុងពេលតែមួយ**

ក្នុងករណីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាព និង ប្រកាសនីយបត្រតក្កកម្មជាតិ មានកាលបរិច្ឆេទសុំចុះបញ្ជីដូចគ្នា ឬ ប្រសិនបើកាលបរិច្ឆេទអាទិភាពដែលមានការប្រកាសអាទិភាពដូចគ្នាត្រូវបានផ្តល់ឲ្យបុគ្គលដែលជាម្ចាស់តែមួយ ឬផ្តល់ឲ្យអ្នកស្នងមរតករបស់គាត់សម្រាប់តក្កកម្មដូចគ្នានោះ ប្រកាសនីយបត្រតក្កកម្មជាតិ ដែលដូចគ្នាទៅនឹងតក្កកម្មនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពនឹងមិនមានប្រសិទ្ធភាពទេ ដោយគិតចាប់ពីកាលបរិច្ឆេទផុតកំណត់នៃការប្តឹងជំទាស់ទៅនឹង ការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបឬគិតចាប់ពីកាលបរិច្ឆេទទទួលយកការសម្រេចចុងក្រោយនៃប្រកាសនីយបត្រតក្កកម្ម អឺរ៉ុប។[83]

**ង. ការបង់ប្រាក់កម្រៃ**

កម្រៃនៃការទទួលស្គាល់សុពលភាពត្រូវអនុវត្តដូចខាងក្រោម៖

- កម្រៃនៃការទទួលស្គាល់សុពលភាពត្រូវបានបង់នៅ ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប បន្ទាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយសុពលភាពនេះក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបោះពុម្ពផ្សាយរបាយការណ៍ការស្រាវជ្រាវអឺរ៉ុប ប៉ុន្តែមិនត្រូវលើសពីរយៈពេល ៦ខែ នៃកាលបរិច្ឆេទនោះ ឬ នៅក្នុងអំឡុងពេលអនុវត្តការងារដែលបានតម្រូវសម្រាប់ចូលទៅក្នុងដំណាក់កាលអឺរ៉ុបនៃសំណុំលិខិតស្នើសុំអន្តរជាតិ។

[82] ប្រការ ១១ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

[83] ប្រការ ១២ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

- កម្រៃនៃការទទួលស្គាល់សុពលភាព នៅតែអាចអនុញ្ញាតឲ្យបង់នៅក្នុងរយៈពេលបន្ថែមចំនួន២ខែបន្ទាប់ពីផុតរយៈពេល ប៉ុន្តែតម្រូវឲ្យបង់កម្រៃបន្ថែមចំនួន៥០%នៅក្នុងរយៈពេលបន្ថែមនេះ។
- ការបង់កម្រៃនៃការទទួលស្គាល់សុពលភាពត្រូវអនុវត្តដូចគ្នាដោយ អនុលោមតាមបទបញ្ញាទាក់ទងទៅ នឹងការបង់កម្រៃរបស់ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។ កម្រៃនៃការទទួលស្គាល់សុពលភាពដែលបានបង់រួចហើយ មិនអាចដកវិញបាន។[84]

កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលមានសុពលភាពការបង់កម្រៃប្រចាំឆ្នាំខាងលើនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

- កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពនៅកម្ពុជា ត្រូវបង់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ឆ្នាំជាបន្តបន្ទាប់រាប់គិតបន្ទាប់ពីឆ្នាំនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវបានបោះពុម្ពផ្សាយនោះ។
- ប្រសិនបើកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពបានបង់ក្នុងរយៈពេល ២ខែ ចាប់ពីពេលដែលការផ្តល់ប្រកាសនីយបត្រតក្កកម្មត្រូវបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នឹងត្រូវចាត់ទុកថាបានបង់ប្រាក់ត្រឹមត្រូវនៅក្នុងឆ្នាំនោះ។

ការបង់កម្រៃសេវាសាធារណៈនៅកម្ពុជា ការបង់កម្រៃ និងសេវាផ្សេងៗនៅកម្ពុជា ដែលពាក់ព័ន្ធនឹងការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ត្រូវអនុវត្តតាមប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរវាងក្រសួងឧស្សាហកម្មនិង សិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[85]

## **៤.៤.ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា**

ប្រកាសស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជាចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៨ មានគោលបំណងអនុវត្តការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិននៅកម្ពុជា ដោយអនុលោមតាមច្បាប់ ប្រកាស

[84] ប្រការ ១៤ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

[85] ប្រការ ១៥ នៃប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្ម អឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

នីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និង អនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញារវាងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជានិងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន។[86]

ប្រកាសនេះ មានគោលដៅ ៖

- កំណត់អំពីនីតិវិធីនៃការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា
- កំណត់បែបបទនៃការរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា
- កំណត់យន្តការទទួលបន្ទុកពិនិត្យនិងគ្រប់គ្រងប្រកាសនីយបត្រតក្កកម្មចិនដែលត្រូវបានទទួលស្គាល់នៅកម្ពុជា។[87]

### ៤.៤.១ សមត្ថកិច្ចទទួលពាក្យស្នើសុំនិងចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិន

ការដាក់ពាក្យស្នើសុំ និងការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជាត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។[88]

### ៤.៤.២ ការដាក់ស្នើសុំ និងចុះបញ្ជី

#### ក. ទម្រង់ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា

ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបំពេញតាមគំរូលិខិតយថាភូត ឲ្យបានត្រឹមត្រូវនូវ ៖

- ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋានរបស់អ្នកដាក់ពាក្យសុំនីមួយៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំនីមួយៗ ផងដែរ។
- ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារពាក្យសុំចុះបញ្ជីត្រូវបញ្ជាក់និងបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ និងត្រូវមានលិខិតផ្ទេរសិទ្ធិតំណាងភ្ជាប់មកជាមួយ។
- ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖
    - ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ថា

[86] ប្រការ ១ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជាចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[87] ប្រការ ២ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[88] ប្រការ ៥ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជាចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

បានចម្លងត្រឹមត្រូវ តាមច្បាប់ដើមពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន។

- ឯកសារចម្លងសេចក្តីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្មចិន ដោយមានការបញ្ជាក់ពីអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ដែលបានផ្តល់រួមមានៈ សេចក្តីអធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប គំនូរបង្ហាញ (ប្រសិនបើមាន)
- ឯកសារបកប្រែជាភាសាខ្មែរ ដែលទាក់ទងត្រូវផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦ខែ គិតចាប់ពីកាលបរិច្ឆេទដែលបានដាក់សំណើសុំចុះបញ្ជី ទៅមន្ត្រីកាន់កាប់បញ្ជី។

- ការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបង់កម្រៃសេវាស្របតាមប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ។[89]

**ខ. ការត្រួតពិនិត្យលើពាក្យស្នើសុំ**

ការត្រួតពិនិត្យលើពាក្យស្នើសុំត្រូវអនុវត្តដូចខាងក្រោមៈ

- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលភាពត្រឹមត្រូវនូវលក្ខខណ្ឌតម្រូវសម្រាប់ដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម
- ប្រសិនបើមានតម្រូវការចាំបាច់ណាមួយមន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យសុំមកផ្តល់ឯកសារ កែតម្រូវទាំងអស់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃជូនដំណឹង។
- ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវហើយនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិន និងត្រូវចេញវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មចុះបញ្ជីនោះជូនអ្នកដាក់ពាក្យស្នើសុំ។
- លេខចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិន ត្រូវចុះកំណត់សម្គាល់ដែលផ្តុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ជចប្រត.ច" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួន ប្រាំខ្ទង់ ដែលត្រូវដាក់តាម

[89] ប្រការ ៦ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

លំដាប់លំដោយនៃការចុះបញ្ជី។[90]

**គ. លក្ខខណ្ឌតម្រូវក្នុងការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា**

ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- ត្រូវមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា
- ត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីក្រោយ ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣និងត្រូវស្របតាមមាត្រា៤ និងមាត្រា៩ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។[91]

**ឃ.ការចុះលេខ**

មន្ត្រីកាន់បញ្ជីត្រូវចុះកំណត់សម្គាល់នៅលើឯកសារនីមួយៗ នៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលពាក្យសុំ និងលេខសំណុំលិខិតស្នើសុំដែលផ្គុំដោយអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ចទប្រត.ច" បន្ទាត់ ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាម លំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល។[92]

**ង. កាលបរិច្ឆេទទទួលពាក្យស្នើសុំចុះបញ្ជី**

កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា និងកាលបរិច្ឆេទសុំចុះបញ្ជីទទួលប្រកាសនីយបត្រតក្កកម្មចិន ត្រូវអនុវត្តដូចខាងក្រោម៖

- កាលបរិច្ឆេទទួលពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជាគឺជា កាលបរិច្ឆេទដែលបានទទួលឯកសារទាំងអស់ និងបង់កម្រៃសេវា។
- កាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទដូចគ្នា និងកាលបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅចិន។
- កាលបរិច្ឆេទចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា គឺជាកាលបរិច្ឆេទ

---

[90] ប្រការ ៩ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[91] ប្រការ ៧ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[92] ប្រការ ៨ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

ចេញវិញ្ញាបនបត្រ ចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។[93]

**ច.ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា**

ប្រកាសនីយបត្រតក្កកម្មចិន ដែលចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រកាសនីយបត្រតក្កកម្មចិនដែល ចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវអនុវត្តដូចប្រកាសនីយបត្រតក្កកម្ម ដែលផ្តល់ដោយមន្រ្តីកាន់កាប់បញ្ជី ហើយស្របតាមមាត្រា៣៨ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។
- កាលបរិច្ឆេទនៃការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវដូចគ្នានឹងកាលបរិច្ឆេទនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មចិន ហើយត្រូវស្របតាម មាត្រា៣៨ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។[94]

**ឆ. ការបង់កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ**

ការបង់កចុះបញ្ជី និងកម្រៃប្រចាំឆ្នាំ សម្រាប់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជាត្រូវអនុវត្តដូចខាងក្រោម ៖

- ការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជាត្រូវបង់កម្រៃសេវា ដូចមានចែងក្នុងប្រកាសរួមស្តីពីការពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មចិន ដែលបានចុះបញ្ជីទទួលស្គាល់នៅកម្ពុជា ត្រូវបង់ដោយ រាប់បន្តពីកាលបរិច្ឆេទចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មនោះ ដោយផ្អែកលើកាលបរិច្ឆេទសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម។
- កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ត្រូវបង់ក្នុងរយៈពេល ៣ ខែ ចាប់ពីកាលបរិច្ឆេទជូនដំណឹងបង់ប្រាក់។[95]

[93] ប្រការ ១០ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[94] ប្រការ ១១ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋ ប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

[95] ប្រការ ១២ នៃប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋ ប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

# សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយខាងលើ អំពីនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប្រតក្កកម្ម យើងឃើញថាមានភាពដូចគ្នាមួយចំនួន។ ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជានិង តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម សុទ្ធតែមានគោលបំណងក្នុងការជួយការពារដល់តក្កករចំពោះ ការរកឃើញនូវតក្កកម្មថ្មីៗ និងជួយជំរុញលើកទឹកចិត្តបុគ្គលគ្រប់រូបក្នុងការរកឃើញអ្វីដែលថ្មី និងមានប្រយោជន៍ដល់ផ្នែកឧស្សាហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ លើសពីនេះតក្កករដែលទទួលបានការការពារចំពោះតក្កកម្មរបស់គាត់នៅកម្ពុជា និងតាមសន្ធិសញ្ញា PCT នឹងទទួលបានសិទ្ធពេញលេញក្នុងការគ្រប់គ្រង និង ប្រើប្រាស់តក្កកម្មរបស់ខ្លួនព្រមទាំងទទួលបានផលប្រយោជន៍ខ្ពស់ក្នុងទីផ្សារ។ តួយ៉ាង ចំពោះនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និងតាមសន្ធិសញ្ញាPCT សុទ្ធតែតម្រូវឲ្យអ្នកដាក់ពាក្យសុំត្រូវបំពេញនូវលក្ខខណ្ឌសំណុំលិខិតដាក់ពាក្យសុំដូចគ្នា ដែលក្នុងនោះរួមមាន ពាក្យសុំសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញ និងខ្លឹមសារសង្ខេបនៃតក្កកម្ម ដើម្បីឲ្យសមត្ថកិច្ចនៃការចុះបញ្ជីអាចធ្វើការស្រាវជ្រាវបញ្ជាក់ពីភាពថ្មី ជំហាននៃការរកឃើញថ្មី និងការអនុវត្តន៍បានក្នុងវិស័យឧស្សាហកម្ម ឬក៏សិប្បកម្ម។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលនៃការចុះបញ្ជី យើងឃើញមានលក្ខណៈខុសគ្នាមួយចំនួនផងដែរ។ សមត្ថកិច្ចដែលទទួលបន្ទុកចុះបញ្ជីនៅកម្ពុជា គឺមានតែនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្មរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានតែប្រធាននាយកដ្ឋានមួយរូបដែលមានតួនាទីដឹកនាំការស្នើសុំចុះបញ្ជីគឺជាមន្ត្រីកាន់កាប់បញ្ជី។ ប៉ុន្តែចំពោះសន្ធិសញ្ញា PCT វិញ សមត្ថកិច្ចក្នុងការចុះបញ្ជីមានសន្និបាត គណៈកម្មាករប្រតិបត្តិការិយាល័យអន្តរជាតិនិង គណៈកម្មការសហប្រតិបត្តិការបច្ចេកទេស ដែលការបែងចែកបានរំលេចនូវតួនាទីនិង ភារៈកិច្ចដាច់ដោយឡែកនិង ច្បាស់លាស់ ដែលមានសារៈសំខាន់ក្នុងការជួយពន្លឿនដល់ការដាក់ពាក្យសុំ។ លើសពីនេះ សន្ធិសញ្ញា PCT ក៏បានបែងចែកកម្រិតនៃការចុះបញ្ជីជា ២ផងដែរ គឺថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ រីឯកម្ពុជាមានតែថ្នាក់ជាតិប៉ុណ្ណោះ ដែលនេះបញ្ជាក់ថាការចុះបញ្ជីតាមសន្ធិសញ្ញា PCT មានលក្ខណៈលម្អិតនិង ការការពារទូលំទូលាយជាង។ ជាងនេះទៅទៀត សន្ធិសញ្ញា PCT មានការផ្សព្វផ្សាយជាសាធារណៈអន្តរជាតិនិង នីតិវិធីនៃការ

ស្រាវជ្រាវអន្តរជាតិបន្ថែម ដែលកម្ពុជាពុំមាន។ ការផ្សព្វផ្សាយជាសាធារណៈអន្តរជាតិ និង នីតិវិធីនៃការស្រាវជ្រាវអន្តរជាតិបន្ថែម បានសឲ្យឃើញថាការផ្សាយព័ត៌មានមានភាពទូលំទូលាយ អំពីតក្កកម្មថ្មីដែលទទួលបានការការពារ ហើយមានការពិនិត្យស្រាវជ្រាវបានលម្អិត និង ស៊ីជម្រៅ ជាងកម្ពុជា ព្រមទាំងមានការការពារ និងទទួលស្គាល់មានលក្ខណៈជាសាកលនិង អន្តរជាតិ ជាមួយប្រទេសជាច្រើនដែលជាសមាជិករបស់ខ្លួន។

ដូច្នេះ ការចុះបញ្ជីតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មបានផ្តល់ផល ព្រោះវាផ្តល់ការការពារដល់អ្នកដាក់ពាក្យសុំដើម្បីទទួលបានការការពារ ពីប្រទេសជាច្រើនដែលជាសមាជិកនៃសន្ធិសញ្ញានេះ។ ហេតុនេះ ចំពោះអ្នកដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅប្រទេសដទៃដែលមិនបានចុះកិច្ចព្រមព្រៀងក្នុងការចុះបញ្ជីស្តីពីការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា ក៏ដូចជាប្រទេសចិន សិង្ហបុរី ជប៉ុន និង សហភាពអ៊ឺរ៉ុប ដែលបានចុះកិច្ចព្រមព្រៀងស្តីពីការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជាប្រសិនបើមានបំណងចង់ទទួលបានការការពារនៅកម្ពុជា ពួកគេគួរតែដាក់ពាក្យសុំតាមរយៈសន្ធិសញ្ញា PCTនេះ ពីព្រោះ ពួកគេនឹងទទួលបានការការពារច្រើនពីប្រទេសជាសមាជិក រួមមានកម្ពុជាផងដែរ។ ដូចគ្នានេះដែរ អ្នកដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា អាចចុះបញ្ជីការពារតាមសន្ធិសញ្ញា PCT បានផងដែរ ដើម្បីទទួលបានការការពារជាអន្តរជាតិ និងចំណេញពេលវេលា ព្រមទាំងថវិកាបានច្រើនជាងការដាក់ពាក្យសុំតាមប្រទេសមួយៗ។

ដោយសារប្រទេសកម្ពុជាទើបចូលជាសមាជិកនៃសន្ធិសញ្ញានេះ ដូច្នេះចំណេះដឹងដែលពាក់ព័ន្ធនឹងសន្ធិសញ្ញានេះនៅថ្មីនៅមានកម្រិតនៅឡើយ។ ហេតុនេះ រដ្ឋាភិបាល រួមជាមួយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ គួរតែធ្វើការផ្សព្វផ្សាយឲ្យកាន់ទូលំទូលាយតាមរយៈការធ្វើសិក្ខាសិលា ឬ ការរៀបចំវគ្គបណ្តុះ បណ្តាលដល់សិស្សានុសិស្ស និងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីឲ្យពួកគេទទួលបានចំណេះដឹងស៊ីជម្រៅនិង ច្បាស់លាស់។

សេដ្ឋកិច្ច និងធនធានមនុស្សនៅកម្ពុជាកំពុងមានការរីកចម្រើន ដែលជាមូលហេតុជួយឲ្យវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាមានការកើនឡើងផងដែរ។ ដូច្នេះ ការពង្រឹងនៃការអនុវត្តច្បាប់នៅកម្ពុជាត្រូវតែមានភាពច្បាស់លាស់ និងមានប្រសិទ្ធិភាពបំផុត ដើម្បីទាក់ទាញឲ្យមានការកើនឡើងនូវចំនួនអ្នកវិនិយោគដោយផ្ទាល់ពីបរទេស។

ជាពិសេសការផ្ទេរបច្ចេកវិទ្យាពីបណ្តាលប្រទេសឧស្សាហកម្មជឿនលឿនចូលមក ព្រះរាជណាចក្រកម្ពុជា ក្នុងទិសដៅជួយអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសកម្ពុជា ដើម្បីបង្កើតនូវ បច្ចេកទេស និងការច្នៃប្រឌិតថ្មី ដោយប្រជាជនកម្ពុជាខ្លួនឯង។

# ឯកសារយោង

- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម នៅកម្ពុជា ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០២

- សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ចុះឆ្នាំ ១៩៧៨

- ប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៦

- ប្រកាសលេខ ១៨១ MIH/2016 ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

- ប្រកាសលេខ ១៨២ MIH/2016 ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦

- ប្រកាសលេខ ២៨២ MIH/2017 ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧

- ប្រកាសលេខ ០៨០ MIH/2018 ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅកម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ២០១៨

# ឧបសម្ព័ន្ធ